# លទ្ធផលនៃការសង្កេតដោយសង្ខេប

រដ្ឋសភាជាតិក្នុងឆមាសដំបូង (កញ្ញា ២០១៣ ដល់ កុម្ភៈ២០១៤) រដ្ឋសភាបានចាប់ផ្តើមនីតិកាលទី៥ របស់ខ្លួន នៅបន្ទាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ក្នុងឆ្នាំ២០១៣។ មានបញ្ហាបធិវាទ និងខ្វះនិត្យានុកូលភាពក្នុងការបង្កើតរដ្ឋសភានីតិកាលនេះ ដែលត្រូវបានបង្កើតឡើងក្រោមការរិះគន់ពីសំណាក់សហគមជាតិ អន្តរជាតិ ជាពិសេសម្ចាស់ឆ្នោតដែលបានបោះឆ្នោតឲ្យគណបក្សសង្គ្រោះជាតិ។ រដ្ឋសភានេះ មិនមានតំណាងរាស្ត្រយ៉ាងតិច១២០នាក់ ព្រោះថាបេក្ខជនជាប់ឆ្នោត៥៥នាក់នៃគណបក្សសង្គ្រោះជាតិមិនទាន់យកសពុលភាពនៅឡើយ។

ក្នុងរយៈពេលនេះមានរបៀបវារៈចំនួន១៣ ត្រូវបានរដ្ឋសភាឯកបក្សបាន និងអនុម័ត តែស្ទើរគ្មានការពិភាក្សាដែលក្នុងនោះ មានរបៀបវារៈចំនួន១០ តម្រូវឲ្យមានការពិភាក្សា និងអនុម័ត និងរបៀបវារៈចំនួន៣ទៀតតម្រូវឲ្យមានការបោះឆ្នោត។

ក្នុងឆមាសដំបូងនេះមានព្រឹត្តការណ៍សំខាន់ៗជាងច្រើនទាក់ទងរដ្ឋសភាដែលរបាយការណ៍នេះលើកមកបង្ហាញដូចជាៈ បដិវាទនៃការអនុវត្តន៍រដ្ឋធម្មនុញ្ញ ក្នុងការបង្កើតក្បាលម៉ាស៊ីនដឹកនាំរដ្ឋ ដំណើរការប្រជុំពេញអង្គរដ្ឋសភា សកម្មភាពរបស់អ្នកតំណាងរាស្ត្រ និងបេក្ខជនជាប់ឆ្នោត ភាពចម្រូងចម្រាសក្នុងការកោះប្រជុំសភាដំបូងរបស់ព្រះមហាក្សត្រ ការចរចារកដំណោះស្រាយនៅក្រោយការបោះឆ្នោតរបស់គណបក្សជាប់ឆ្នោត ការមិនចូលសភារបស់បេក្ខជនជាប់ឆ្នោនៃគណបក្សសង្គ្រោះជាតិ និងរដ្ឋសភាឯកបក្សទទួលរងការរិះគន់ជាដើម។

ក្នុងអំឡុងពេលនេះ មានសកម្មភាពរបស់តំណាងរាស្ត្រនិងបេក្ខជនជាប់ឆ្នោតគណបក្សទាំងពីរចុះមូលដ្ឋានភាគច្រើនគឺចុះសួរសុខទុក្ខប្រជាពលរដ្ឋ ប៉ុន្តែគ្មានសកម្មភាពណាជួយអន្តរាគមន៍ដោះស្រាយបញ្ហារបស់របស់ប្រជាពលរដ្ឋ។

## I. បដិវាទនៃការអនុវត្តន៍រដ្ឋធម្មនុញ្ញ ក្នុងការបង្កើតក្បាលម៉ាស៊ីនដឹកនាំរដ្ឋសភា

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល) បានចូលរួមអង្កេត និងតាមដានដំណើរនៃការផ្ទេរអំណាច និងជំលោះនៃក្រោយការបោះឆ្នោត។ ចំណុចខាងក្រោមនេះនឹងពិភាក្សាអំពីបដិវាទនៃការអនុវត្តន៍រដ្ឋធម្មនុញ្ញក្នុងការបង្កើតរដ្ឋសភា និងរាជរដ្ឋាភិបាលថ្មី ក្រោយពី គ.ជ.ប បានប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥។

### ១.១ ការបង្កើតរដ្ឋសភា

លទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) កាលពីថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៣ បានបង្ហាញ ថា គណបក្សប្រជាជនកម្ពុជាគឺជាគណបក្សទទួលបានបេក្ខជនជាប់ឆ្នោតចំនួន៦៨នាក់ នៃ១២៣អាសនៈនៃរដ្ឋសភា។ ចំណែកឯគណបក្សសង្គ្រោះជាតិទទួលបានបេក្ខជនជាប់ឆ្នោត៥៥នាក់។ បើយោងច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងរដ្ឋធម្មនុញ្ញបានកំណត់ពីរការខុសគ្នាក្នុងដំណាក់កាលដើម្បីបានជាឋានៈជាប្រភេទបេក្ខជនជាប់ឆ្នោត ប្រភេទសមាជិកសភានិងប្រភេទ តំណាងរាស្ត្រ។

រាល់ប្រភេទនីមួយៗគឺមាននីតិវិធីផ្តល់សុពលភាព។ ទោះបីជាក្រុមអ្នកច្បាប់របស់គណបក្សប្រជាជនកម្ពុជា បានព្យាយាមបកស្រាយថា វត្តមានតំណាងរាស្ត្រមានចាប់តាំងពីពេលបោះឆ្នោត ប៉ុន្តែ គ.ជ.ប អាចផ្តល់សុពលភាពពួកគេត្រឹមតែជា "បេក្ខជនជាប់ឆ្នោត" មិនទាន់បានផ្តល់សុពលភាពពួកគេជា «តំណាងរាស្ត្រ» បាននោះទេ។ នៅក្នុងបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភាជំពូកទី២បាននិយាយអំពីសុពលភាពនៃអ្នកតំណាងរាស្ត្រហេតុដូច្នេះហើយគេត្រូវការផ្តល់សុពលភាពពី «បេក្ខជនជាប់ឆ្នោត» ទៅ «សមាជិកតំណាងរាស្ត្រ» នៅពេលបង្កើត រដ្ឋសភានៃនីតិកាលថ្មីសមាជិកតំណាងរាស្ត្រក្លាយជាសមាជិកសភានៅពេលអ្នកតំណាងរាស្ត្រជាសមាជិកនៃរចនាសម្ព័ន្ធរដ្ឋសភា។

**រូបសញ្ញាគណបក្សប្រើក្នុងរបាយការណ៍នេះ៖**

គណបក្ស ប្រជាជនកម្ពុជា

គណបក្ស សង្គ្រោះជាតិ

ក្នុងដំណើរការផ្តល់សុពលភាព មាននីតិវិធីខ្លះដែលកំពុងមានភាពចម្រូង ចម្រាស់ក្នុងការបកស្រាយ ការបើកសម័យប្រជុំសភាដំបូង ក្រោមព្រះរាជា ធិបតីភាពព្រះមហាក្សត្រ ឬ/និងការបិទឈ្មោះអ្នកតំណាងរាស្ត្រនៅរដ្ឋសភា ឬ/និងការធ្វើសច្ចាប្រណិធានចូលកាន់ដំណែង។ ជាគោលការណ៍នៃប្រទេសប្រជាធិបតេយ្យ ការធ្វើសច្ចាប្រណិធានចូលកាន់ដំណែង គឺជាការផ្តល់ សុពលភាព បេក្ខជនជាប់ឆ្នោត ឬតំណាងរាស្ត្រក្លាយជាសមាជិកសភា ដែលនឹងអាចបំពេញមុខងារ និងតួនាទីនៅក្នុងគណៈកម្មការជំនាញធ្វើការពិភាក្សា ទទួលបានប្រាក់ខែ ឬប្រាក់បំណាច់របស់សភា និងមានអភ័យឯកសិទ្ធិសភា។ នៅកម្ពុជា បានអាណត្តិសមាជិកសភាមានវិសមត្ថភាពជាមួយការបំពេញមុខងារសាធារណៈ ជាសកម្ម និងជាមួយមុខងារជាសមាជិកនៃស្ថាប័នដទៃទៀត យោងតាម មាត្រា៧៩នៃរដ្ឋធម្មនុញ្ញ។

ផ្អែកលើកំណត់ហេតុជាផ្លូវការនៃការបកស្រាយបំភ្លឺរបស់ក្រុមប្រឹក្សាធម្មនុញ្ញ កាលពីថ្ងៃទី ២២ ខែកក្កដា ឆ្នាំ ២០០៣ ទាក់ទិននឹងបញ្ហាខាងលើនេះ ក្រុមប្រឹក្សាធម្មនុញ្ញបានបកស្រាយបំភ្លឺយ៉ាងច្បាស់ជាលាយលក្ខណ៍អក្សរលើខ្លឹមសារវាក្យខណ្ឌទី១ មាត្រា ៧៦ នៃច្បាប់ធម្មនុញ្ញ៖ «វាក្យខណ្ឌទី១ មាត្រា ៧៦ នៃច្បាប់រដ្ឋធម្មនុញ្ញថា៖ រដ្ឋសភាមានសមាជិកជាតំណាងរាស្ត្រយ៉ាងតិច ១២០ រូប។ ត្រង់នេះ មានន័យថា យ៉ាងតិចណាស់ត្រូវមាន"**សមាជិកតំណាងរាស្ត្រចំនួន១២០រូប ទើបអាចបង្កើតរដ្ឋសភាក្នុងនីតិកាលនីមួយៗបាន**"។

**មាតិកាសំខាន់ៗ**


I. បដិវាទនៃការអនុវត្តន៍រដ្ឋធម្មនុញ្ញក្នុងការបង្កើតក្បាលម៉ាស៊ីនដឹកនាំរដ្ឋ ទំព័រទី ១

II. ដំណើរការប្រជុំពេញអង្គរដ្ឋសភា ទំព័រទី ៦

III. សកម្មភាពតំណាងរាស្ត្រ និងតំណាងជាប់ឆ្នោត ទំព័រ


តាមវាក្យខ័ណ្ឌទី១ មាត្រា ៨២ រដ្ឋសភាបើកកិច្ចប្រជុំដំបូង៦០ថ្ងៃយ៉ាងយូរក្រោយពេលបោះឆ្នោត ក្រោមការកោះប្រជុំ របស់ព្រះមហាក្សត្រ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានផ្តល់សុពលភាពដល់បេក្ខជនជាប់ឆ្នោតតែប៉ុណ្ណោះ ដូច្នេះបេក្ខជនទាំងនោះមិនទាន់ត្រូវបានក្លាយជាសមាជិកតំណាងរាស្ត្រនោះទេ។ ចំពោះវាក្យខ័ណ្ឌទី២ នៃមាត្រា ៨២ខាងលើ បានចែងថា មុនចាប់ផ្តើមការងាររបស់

ខ្លួន រដ្ឋសភាត្រូវប្រកាសសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ។ វាក្យខណ្ឌនេះ សំដៅទៅលើការប្រកាសសុពលភាពនៃអាណត្តិរបស់សមាជិករដ្ឋសភា មិនមែនប្រកាសសុពលភាពរបស់តំណាងរាស្ត្រនោះទេ។

តាមវាក្យខណ្ឌទី១មាត្រា ៧៦ និងតាមវាក្យខណ្ឌទី១ មាត្រា ៨២ ខាងលើ ការបង្កើតរដ្ឋសភានីតិកាលថ្មី គឺតម្រូវឲ្យមានមាសជិកតំណាងរាស្ត្រយ៉ាងតិច១២០រូប និងបើកការប្រជុំដំបូងក្រោមព្រះរាជាធិបតីភាពព្រះមហាក្សត្រ។ ប៉ុន្តែមិនមានមាត្រាណាមួយចង្អុលបង្ហាញថា សមាជិកយ៉ាងតិច១២០រូបត្រូវតែមានវត្តមាន ក្នុងកិច្ចប្រជុំដំបូងនោះទេ។ នេះជាចំណុចដែលមានការមិនច្បាស់លាស់ថា តើនេះជានីតិវិធីក្នុងការផ្តល់សុពលភាពបេក្ខជនជាប់ឆ្នោតទៅជាអ្នកតំណាងរាស្ត្រឬទេ។

មានសំណួរលើកឡើងថា តើគេត្រូវដោះស្រាយដូចម្តេចនៅពេលបេក្ខជនជាប់ឆ្នោតត្រឹមតែ ០៤នាក់មិនទទួលយកសុពលភាព។ ត្រង់នេះគឺបណ្តាលឲ្យជាប់គាំងក្នុងការបង្កើតរដ្ឋសភា និងរដ្ឋភិបាល។ ប្រព័ន្ធនេះគឺ អយុត្តិធម៌ចំពោះគណបក្សជាប់ឆ្នោតច្រើនជាងគេដោយសារតែបង្កើតរដ្ឋាភិបាលមិនបាន។

កន្លងមកមានការបកស្រាយដោយគណបក្សប្រជាជនកម្ពុជាថា មាត្រា១១៨ និង ១២០នៃច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រមានន័យថា បើបេក្ខជនជាប់ឆ្នោតមិនយកសុពលភាព នោះ គ.ជ.ប យក អាសនៈទៅបែងចែកឲ្យគណបក្សដែលមានអាសនៈក្នុងរដ្ឋសភា។

ចំពោះស្ថានភាពក្រោយការបោះឆ្នោតឆ្នាំ២០០៨ និង២០១៣គណបក្សប្រជាជនកម្ពុជា និងលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ធ្លាប់បានព្រមានគណបក្សប្រឆាំងថា អាសនៈរបស់គណបក្សប្រឆាំង នឹងត្រូវយកទៅបែងចែកឲ្យគណបក្សដទៃទៀតដែលមានអាសនៈក្នុងរដ្ឋសភា ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ប្រសិនបើគណបក្សប្រឆាំងនេះបោះបង់អាសនៈរបស់ខ្លួន បើយោងតាមមាត្រា១១៨ និងមាត្រា១២០នៃច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។

ក្រោយពេលបោះឆ្នោតឆ្នាំ២០០៨ មានការព្រមានចំពោះគណបក្សសិទ្ធិមនុស្ស និងគណបក្សសម រង្ស៊ី អាចនឹងប្រឈមនឹងការបាត់បង់អាសនៈក្នុងរដ្ឋសភាដោយសារ គ.ជ.ប នឹងយកអាសនៈរបស់គណបក្សទាំងនោះទៅ បែងចែកឲ្យគណបក្សផ្សេងទៀតដែលបានជាប់ឆ្នោត ប្រសិនបើគណបក្សនេះធ្វើពហិកាមិនចូលរួមប្រជុំសភាដំបូង។ អ្វីដែលខុសគ្នាចំពោះស្ថានភាពទាំងពីរនោះ គឺសម្រាប់ការបោះឆ្នោតឆ្នាំ២០០៨ បើទោះបីជា គ.ជ.ប យកអាសនៈរបស់ គណបក្ស សមរង្ស៊ី និងគណបក្សសិទ្ធិមនុស្សទៅបែងចែកឲ្យគណបក្សដែលជាប់ឆ្នោត ក៏រដ្ឋសភានៅតែមានពហុបក្សដដែល ព្រោះ គណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សនរោត្តម រណឫទ្ធិ ក៏ជាប់ឆ្នោតក្នុងឆ្នាំ២០០៨ផងដែរ។ ដូចនេះក្នុងស្ថានភាពពេលនោះ ការបែងចែកអាសនៈរបស់គណបក្សទាំងពីរមិនធ្វើឲ្យរដ្ឋសភាក្លាយទៅជារដ្ឋសភាឯកបក្ស។ ដោយសារសម្ពាធដូចនេះហើយទើបគណបក្សសមរង្ស៊ីបានធ្វើការសម្រេចចូលរួមក្នុងសភានីតិកាលទី៤នៅ ដំណាក់ចុងក្រោយ។

ខុសពីស្ថានភាពក្រោយពេលបោះឆ្នោតឆ្នាំ២០០៨ បើ គ.ជ.ប យកអាសនៈរបស់គណបក្សសង្គ្រោះជាតិឲ្យគណបក្សជាប់ឆ្នោត នោះអាសនៈទាំង១២៣នឹងបានទៅគណបក្សប្រជាជនកម្ពុជា។ ក្នុងស្ថានការណ៍ថ្មីនេះ អ្នកច្បាប់ និងវាគ្មិនគាំទ្រគណបក្សប្រជាជនកម្ពុជាបានបកស្រាយពីការបង្កើតអាណត្តិសភាថ្មី ឬការផ្តល់សុពលភាពដល់អ្នកតំណាងរាស្ត្របានកើត

ឡើងតាំងពីពេលបោះឆ្នោតហើយបានពន្យល់ថា អ្នកតំណាង១២៣នាក់ គឺគ្រាន់តែជាតម្រូវការកំណត់ចំនួននៅក្នុងច្បាប់បោះឆ្នោតទេ។

ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៣ គឺជាការបរិច្ឆេទនៃកិច្ចប្រជុំដំបូងនៃការបង្កើតរដ្ឋសភានីតិកាលទី៥។ វាក្យខណ្ឌទី០១ មាត្រា ៨២ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានចែងថា រដ្ឋសភាបើកសម័យប្រជុំដំបូង៦០ថ្ងៃយ៉ាងយូរ**«ក្រោយពេលបោះឆ្នោត»** តាមការកោះប្រជុំរបស់ព្រះមហាក្សត្រ។ ខុមហ្វ្រែលយល់ថា ជាបច្ចេកទេសនៅមានរយៈច្រើនក្នុងការអនុវត្តន៍មាត្រា៨២ខាងលើ ព្រោះថា «ក្រោយការបោះឆ្នោត» គឺនិយាយទៅដល់ពេលបញ្ចប់ការបោះឆ្នោត ឬពេលប្រកាសលទ្ធផលបោះឆ្នោតចុងក្រោយ។ ដូចនេះក្រោយពេលបោះឆ្នោតគឺ ចាប់តាំងពីក្រោយថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៣ ដែលគណៈ កម្មាធិការជាតិរៀបចំការបោះឆ្នោតបានប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោតនោះ។ កិច្ចប្រជុំរដ្ឋសភាដំបូងដែលឆ្លើយតប តាមមាត្រា៨២ខាងលើ អាចត្រូវបានពន្យារពេលរហូតដល់ដើមខែវិច្ឆិកា។ ការពន្យារពេលនេះគឺទុកពេលវេលាឲ្យគណបក្ស ប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិមានពេលវេលាគ្រប់គ្រាន់ដើម្បីចរចាស្វែងរកដំណោះស្រាយជម្លោះក្រោយការបោះ ឆ្នោត។ មាត្រាច្បាប់ខាងលើបានសរសេរថា រដ្ឋសភាបើកសម័យប្រជុំដំបូង៦០ថ្ងៃយ៉ាងយូរក្រោយពេលបោះឆ្នោត។ ក្រោយ ពេលបោះឆ្នោតសំដៅទៅលើពេលដែលដំណើរនៃការបោះឆ្នោតទាំងមូលបានបញ្ចប់ មានន័យថា ក្រោយការបោះឆ្នោតទទួល បានលទ្ធផលផ្លូវការ មិនមែនសំដៅទៅលើក្រោយកាលបរិច្ឆេទណាមួយដែលបានកំណត់ក្នុងប្រតិទិនបោះឆ្នោតដូចជាថ្ងៃបោះឆ្នោតជាដើមនោះទេ។

នៅក្នុងកិច្ចប្រជុំរដ្ឋសភាដំបូងកាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៣ មានតែបេក្ខជនជាប់ឆ្នោតជាតំណាងរាស្ត្រចំនួន ៦៨រូបមកពីគណបក្សប្រជាជនកម្ពុជាទេ បានចូលរួមក្នុងកិច្ចប្រជុំដំបូងនោះ ដោយមិនមានវត្តមានបេក្ខជនជាប់ឆ្នោតជាតំណាងរាស្ត្រចំនួន ៥៥រូបរបស់គណបក្សសង្គ្រោះជាតិ។ ក្នុងដំណើរការនេះ បេក្ខជនជាប់ឆ្នោត ចំនួន៦៨រូបមកពីគណបក្សប្រជាជនកម្ពុជា បានក្លាយជាសមាជិកជាតំណាងរាស្ត្រខណៈពេលដែលបេក្ខជនជាប់ឆ្នោត ៥៥រូបរបស់គណបក្សសង្គ្រោះជាតិមិនទាន់ក្លាយជាសមាជិកតំណាងរាស្ត្រនៅឡើយទេ។

ម្យ៉ាងវិញទៀត នេះបង្ហាញថា រដ្ឋសភាត្រូវបានបង្កើតដោយគ្មានការចូលរួមពីពហុបក្ស ក្នុងការឆ្លើយតបនឹងមាត្រា០១ នៃរដ្ឋធម្មនុញ្ញដែលចែងថា ព្រះរាជាណាចក្រកម្ពុជាតាមលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។ ម្យ៉ាងវិញទៀតការបើកប្រជុំបង្កើតរដ្ឋសភាដំបូងក្រោមព្រះរាជាធិបតីភាពរបស់ព្រះមហាក្សត្រ ដែលមិនទាន់មានឯកភាពជាតិ ដូច្នេះគឺពិតជាមិនបានអនុវត្តតាមមាត្រា០៨នៃរដ្ឋធម្មនុញ្ញដែលបានចែងត្រង់វាក្យខ័ណ្ឌទី១ថា ព្រះមហាក្សត្រព្រះអង្គជានិមិត្តរូបនៃឯកភាពជាតិ។

ដំណើរការ និងនីតិវីធីនាពេលបច្ចុប្បន្ន គឺពឹងផ្អែកទាំងស្រុងទៅលើឆន្ទៈគណបក្សនយោបាយតែមួយគត់ ហើយក្នុងបរិបទនយោបាយប្រទេសកម្ពុជា គណបក្សនយោបាយមានអំណាច និងមានឥទ្ធិពលក្នុងការគ្រប់គ្រងបេក្ខជនជាប់ឆ្នោត ឬតំណាងរាស្ត្ររបស់គណបក្សខ្លួន។

## ១.២ ការតែងតាំងថ្នាក់ដឹកនាំរដ្ឋសភា និងរាជរដ្ឋាភិបាល

មាត្រា ៨២ថ្មី នៃរដ្ឋធម្មនុញ្ញ បានចែងថា រដ្ឋសភាត្រូវបោះឆ្នោតដាច់ដោយឡែកពីគ្នានូវប្រធាន និងអនុប្រធានរដ្ឋសភា និងសមាជិកទាំងអស់នៃគណៈកម្មការនានារបស់រដ្ឋសភាដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល។ ចំណែកឯមាត្រា ១១៩ថ្មី បានក៏បានចែងថា វរជនមួយរូបក្នុងចំណោមតំណាងរាស្ត្រនៃគណបក្សឈ្នះឆ្នោត ដែលត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ តាមសេចក្តីស្នើពីប្រធានដោយមានការឯកភាពពីអនុប្រធានរដ្ឋសភាទាំងពីរ នាំសហការីដែលជាតំណាងរាស្ត្រ ឬជាសមាជិកតំណាងគណបក្សនៅក្នុងរដ្ឋសភាដែលផ្គូរផ្គងឲ្យកាន់ដំណែងផ្សេងៗ ក្នុងរាជរដ្ឋាភិបាលទៅសុំ សេចក្តីទុកចិត្តពីរដ្ឋសភា។ យោងតាមវាក្យខ័ណ្ឌចុងក្រោយនៃមាត្រា ៩០ថ្មី(ពីរ) នៃរដ្ឋធម្មនុញ្ញ បានចែងថា រដ្ឋសភាបោះឆ្នោតទុកចិត្តដល់រាជរដ្ឋាភិបាលតាមមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល។ មាត្រានេះមានសារៈសំខាន់ណាស់ដើម្បីអនុវត្តប្រព័ន្ធសភានិយម។ អំណាចរដ្ឋសភាត្រូវខ្លាំងជាងអំណាចរាជរដ្ឋាភិបាល។ ហើយគេត្រូវធានាឲ្យមានការបែងចែកអំណាចឲ្យដាច់ពីគ្នារវាងរដ្ឋាភិបាល និងរដ្ឋសភា យោងតាមមាត្រា៥១ថ្មីនៃរដ្ឋធម្មនុញ្ញ។

ការបោះឆ្នោតជ្រើសតាំង ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មការនានា និងគណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល កម្ពុជានីតិកាលទី៥ នៃសភាជាតិ កាលពីថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣វិញ ដំណើរការនៃការបោះឆ្នោតជ្រើសតាំងខាងលើមិន អនុវត្តតាមនីតិវិធីមាត្រា ៨២ថ្មី និងមាត្រា១១៩ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដែលបានអនុម័តនៅឆ្នាំ ១៩៩៣។ ដំណើរនីតិវិធីនៃការបោះឆ្នោតជ្រើសតាំងប្រធាន អនុប្រធាន និងសមាជិកគណៈកម្មការនានា និងគណៈរដ្ឋមន្ត្រីនៃរាជ រដ្ឋាភិបាលកម្ពុជានីតិកាលទី៥ នៃសភាជាតិ ឆ្នាំ២០១៣ បានធ្វើឡើងតាមការបោះឆ្នោតជាកញ្ចប់ដោយយោងតាមមាត្រា០៤ នៃច្បាប់ធម្មនុញ្ញបន្ថែមដែលបានអនុម័តក្នុងឆ្នាំ២០០៤។ ប៉ុន្តែមាត្រា ៣ នៃច្បាប់ធម្មនុញ្ញបន្ថែមបានចែងយ៉ាងច្បាស់ថា គេ អាចធ្វើការបោះឆ្នោតជាកញ្ចប់ដើម្បីជ្រើសតាំងប្រធាន អនុប្រធានរដ្ឋសភា ក៏ដូចជាប្រធាន និងអនុប្រធានគណៈកម្មការក្នុង ពេលជាមួយគ្នានឹងការផ្តល់សេចក្តីទុកចិត្តចំពោះរាជរដ្ឋាភិបាល ក្នុងករណីដែលឃើញថា នីតិវិធីនៃមាត្រា ៨២ និង ១១៩ ថ្មី នៃរដ្ឋធម្មនុញ្ញមិនអាចសម្រេចបាន។ ដូចនេះគណបក្សប្រជាជនកម្ពុជាមិនអនុវត្តមាត្រា ៨២ថ្មី និង ១១៩ថ្មី នៃរដ្ឋធម្មនុញ្ញបើ ទោះបីគណបក្សនេះសន្មតថា ខ្លួនមានតំណាងរាស្ត្រគ្រប់ចំនួនក្តី។

ផ្អែកតាមលទ្ធផ្លូវការនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រដែលប្រកាសដោយ គ.ជ.ប កាលពីថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៣ គណបក្សប្រជាជនកម្ពុជាទទួលបានចំនួន ៦៨ នៃចំនួនអាសនៈសរុប ១២៣នៃរដ្ឋសភា។ លទ្ធផលនេះបានបង្ហាញយ៉ាងច្បាស់ថា គណបក្សប្រជាជនជាគណបក្សឈ្នះឆ្នោតហើយទទួលបានអាសនៈលើសពីសម្លេងភាគច្រើនដាច់ខាតផងដែរ។ បន្ថែមលើសពីនេះទៀត ក្នុងកិច្ចប្រជុំបោះឆ្នោតជ្រើសតាំង និងផ្តល់សេចក្តីទុកចិត្តខាងលើ គឺមានចំនួនគូរ៉ុមចំនួន ៦៨លើ១២៣រូប ជាសម្លេងលើសមតិភាគច្រើនដាច់ខាតដែលទាមទារឲ្យមានត្រឹមតែ៦២រូបតែប៉ុណ្ណោះ។ ដូចនេះការបោះឆ្នោតជ្រើសតាំង ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាការនានា នៃសភាជាតិ និង គណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល កម្ពុជានីតិកាលទី៥ នៃសភាជាតិ គឺត្រូវអនុវត្តតាមនីតិវិធីនៃមាត្រា ៨២ថ្មី មាត្រា១១៩ថ្មី និងមាត្រា ៩០ថ្មី(ពីរ) នៃរដ្ឋធម្មនុញ្ញ នៃ

ព្រះរាជាណាចក្រកម្ពុជា។ ការធ្វើនីតិវិធីបោះឆ្នោតជាកញ្ចប់ ដោយយោងតាមមាត្រា០៤ នៃច្បាប់ធម្មនុញ្ញបន្ថែមនាពេលនេះ គឺធ្វើឲ្យរដ្ឋសភា និងរាជរដ្ឋាភិបាលខ្វះនីត្យានុកូលភាពក្នុងដំណើរការការងាររបស់ខ្លួន។

សរុបមកការបង្កើតរដ្ឋសភា និងរាជរដ្ឋាភិបាលនីតិកាលទី៥ គឺមានបដិវាទពាក់ព័ន្ធការអនុវត្តន៍នីតិវិធី មាត្រា៧៦ មាត្រា ៨២ថ្មី មាត្រា១១៩ថ្មី និងមាត្រា ៩០ថ្មី(ពីរ)។ ការបង្កើតរដ្ឋសភាមិនគោរពតាមមាត្រា៧៦ ដែលបានកំណត់ថា រដ្ឋសភាត្រូវមានសមាជិកតំណាងរាស្ត្រយ៉ាងតិច១២០រូប ព្រោះថាបេក្ខជនជាប់ឆ្នោត៥៥នាក់របស់គណបក្សសង្គ្រោះជាតិមិនទាន់ក្លាយជាអ្នកតំណាងរាស្ត្រ។ មិនមាននីតិវិធីច្បាស់លាស់មួយស្តីពីការផ្តល់សុពលភាពដើម្បីប្រែក្លាយបេក្ខជនជាប់ឆ្នោតទៅជាអ្នកតំណាងរាស្ត្រ។ បន្ថែមលើសពីនេះទៀត ការបោះឆ្នោតជ្រើសតាំងថ្នាក់ដឹកនាំរដ្ឋសភា និងការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តដល់រាជរដ្ឋាភិបាលមិនបានអនុវត្តតាមមាត្រា៨២ថ្មី និង ១១៩ថ្មី នៃរដ្ឋធម្មនុញ្ញដែលតម្រូវឲ្យមានការបោះឆ្នោតដាច់ដោយឡែកពីគ្នា។ ហើយការអនុវត្តន៍នេះមិនគោរពតាមស្មារតីនៃរដ្ឋធម្មនុញ្ញដែលផ្តោតសំខាន់លើការពង្រឹងឯកភាពជាតិ កសាង ប្រទេសឲ្យទៅជាកោះសន្តិភាពឡើងវិញផ្អែកលើប្រព័ន្ធប្រជាធិបតេយ្យសេរីពហុបក្ស និងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។ បដិវាទនៃការមិនអនុវត្តតាមរដ្ឋធម្មនុញ្ញ និងច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្របាននាំមកនូវការខ្វះនីត្យានុកូលភាព ឬខ្វះភាពត្រឹមត្រូវតាមច្បាប់ក្នុងកំរិតធ្ងន់ធ្ងរ។

## II. ដំណើរការប្រជុំពេញអង្គរដ្ឋសភា

### ២.១ សម័យប្រជុំដំបូងនៃរដ្ឋសភា នីតិកាលទី៥

មានការខ្វែងគំនិតគ្នារវាងមន្ត្រីគណបក្សប្រជាជនកម្ពុជាជាមួយមន្ត្រីគណបក្សសង្គ្រោះជាតិ អ្នកវិភាគឯករាជ្យ និងអ្នកច្បាប់មួយចំនួនចំពោះនីតិវិធីក្នុងការប្រជុំដំបូងនៃរដ្ឋសភា។ អតីតសមាជិកសភា និងអ្នកច្បាប់មួយចំនួនបានអះអាងថា បើសិនជាគ្មានតំណាងរាស្ត្រ ឬបេក្ខជនជាប់ឆ្នោតចំនួន ១២០នាក់ ចូលរួមប្រជុំនៅក្នុងការកោះប្រជុំលើកដំបូងទេ គឺមិនមានការបង្កើតសភាអាណត្តិទី៥ បានឡើយ។ លោកសុក សំអឿន នាយកអង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា បានពន្យល់ថា យោងមាត្រា ៧៦ នៅក្នុងរដ្ឋធម្មនុញ្ញ រដ្ឋសភាត្រូវមានសមាជិកតំណាងរាស្ត្រយ៉ាងតិច ១២០រូប បើមិនដូចនេះទេ គេមិនអាចនិយាយបានថាមានរដ្ឋសភាបានឡើយ។ ជាមួយគ្នានេះមន្ត្រីអតីតតំណាងរាស្ត្រ និងជាមន្ត្រីជាន់ខ្ពស់គណបក្សប្រឆាំងក៏បានបកស្រាយថា សភានីតិកាលទី៥ មិនអាចកើតឡើងបានទេប្រសិនបើមិនមានបេក្ខជនជាប់ឆ្នោតចំនួន ១២០នាក់ចូលរួមប្រជុំដំបូង។ លើសពីនេះ ក៏មានការ លើកឡើងថាការប្រជុំសភាលើកទី១ ដោយមានសមាជិកតំណាងរាស្ត្រ ជាប់ឆ្នោតថ្មីមកពីគណបក្សប្រជាជនកម្ពុជាតែម្នាក់ឯងក្នុង នីតិកាលទី៥នេះ វាមិនមែនជារដ្ឋសភារបស់ជាតិទេ។

ដោយឡែកលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានថ្លែងកាលពីថ្ងៃទី២ សីហា ថាការប្រជុំសភាដើម្បីតែងតាំងរដ្ឋាភិបាលថ្មីត្រូវការកូរ៉ុមសមាជិកសភាចូលប្រជុំតែ ៦៣រូបប៉ុណ្ណោះ។ ជាមួយគ្នានេះបេក្ខជនជាប់ឆ្នោតពីគណបក្សប្រជាជនកម្ពុជាក៏បានអះអាងថាការកោះប្រជុំសភាដំបូងដោយព្រះមហាក្សត្រគឺមិនត្រូវការកូរ៉ុមទេ។ ម្យ៉ាងការយករដ្ឋធម្មនុញ្ញបំពេញបន្ថែមមកអនុវត្តហើយបញ្ហានេះត្រូវបានអនុវត្តរួចហើយកាលពីការបង្កើតសភានីតិកាលទី៤ ឆ្នាំ២០០៨។ ពេលនោះឆ្នាំ២០០៨ក៏មិនមានបេក្ខជនជាប់ឆ្នោត១២០រូបចូលរួមប្រជុំដំបូងដែរ ហើយរដ្ឋសភាត្រូវបានបង្កើត ហើយដំណើរការដល់ចប់អាណត្តិ។

បើពិនិត្យនៅក្នុងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញកាលពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៣ បានចែងទាក់ទងវាក្យខណ្ឌទី១ នៃមាត្រា ៧៦ របស់រដ្ឋធម្មនុញ្ញថា យ៉ាងតិចត្រូវមានសមាជិកជាតំណាងរាស្ត្រ ១២០រូប ទើបអាចបង្កើតរដ្ឋសភាក្នុងនីតិកាលនីមួយៗបាន។ ច្បាប់បោះឆ្នោតមិនអាចកំណត់ចំនួនតំណាងរាស្ត្រតិចជាង ១២០រូបបានឡើយ។

វាក្យខណ្ឌទី១នេះជាលក្ខខ័ណ្ឌចាំបាច់សម្រាប់ការបង្កើតរដ្ឋសភា ប៉ុន្តែមិនមែនសម្រាប់ដំណើរការរដ្ឋសភាទេ។ នៅពេលបោះឆ្នោតចប់ហើយ លទ្ធផលត្រូវឲ្យបានតំណាងរាស្ត្រចាប់ពី ១២០រូបឡើងទៅ តាមការកំណត់នៃច្បាប់បោះឆ្នោតទើបបានអាចបង្កើតរដ្ឋសភានីតិកាលថ្មីមួយបានដោយគោរពទៅតាមនីតិវិធីដែលមានចែងនៅក្នុងមាត្រា ៨២ នៃរដ្ឋធម្មនុញ្ញ និងប្រការ ៣ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា។ គឺថា រដ្ឋសភាដែលកើតចេញពីការបោះឆ្នោតត្រូវចូលកាន់តំណែងជាផ្លូវការនៅពេលសម័យប្រជុំដំបូងតាមការកោះហៅរបស់ព្រះមហាក្សត្រ ហើយនិងមានការប្រកាសសម្រេចសុពលភាពឈ្មោះអ្នកតំណាងរាស្ត្របិទផ្សាយក្នុងមន្ទីររដ្ឋសភា និងជាសាធារណៈ។

បើយោងតាមរដ្ឋធម្មនុញ្ញមាត្រា ៨២ថ្មី បានចែងថា រដ្ឋសភាបើកសម័យប្រជុំដំបូង ហុកសិបថ្ងៃយ៉ាងយូរក្រោយពេលបោះឆ្នោត តាមការកោះប្រជុំរបស់ព្រះមហាក្សត្រ។ មុនចាប់ផ្តើមការងាររបស់ខ្លួន រដ្ឋសភាត្រូវប្រកាសសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ ត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នា នូវប្រធាន អនុប្រធានរដ្ឋសភា និងសមាជិកទាំងអស់នៃគណៈកម្មការនានារបស់រដ្ឋសភា។ ជាមួយគ្នានេះមាត្រា ៦៧ បានចែងថា រដ្ឋសភា មានសមាជិកតំណាងរាស្ត្រយ៉ាងតិច ១២០រូប។

### ២.២ ការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រក្នុងពេលប្រជុំពេញអង្គ

ក្នុងអំឡុងឆមាសដំបូងនៃរដ្ឋសភានីតិកាលទី៥ ចាប់ពីខែកញ្ញា ឆ្នាំ២០១៣ ដល់ខែកុម្ភៈ ឆ្នាំ២០១៤ រដ្ឋសភាបានបើកកិច្ចប្រជុំដំបូងមួយលើក និងកិច្ចប្រជុំពេញអង្គចំនួន ៤លើក ដោយបានយកលើរបៀបវារៈចំនួន១៣ ដែលក្នុងនោះមាន របៀបវារៈចំនួន១០ តម្រូវឲ្យមានការពិភាក្សា និងអនុម័ត និងរបៀបវារៈចំនួន៣ទៀតតម្រូវឲ្យមានការបោះឆ្នោត។

របៀបវារៈចំនួន១០ដែលបានលើកមកពិភាក្សា និងអនុម័តរួមមានដូចជាៈ ការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ (សម្លេងអនុម័ត៦៦/៦៦) ការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម (សម្លេងអនុម័ត៦៦/៦៦) ការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការបង្កើតក្រសួង រ៉ែ និងថាមពលដែលមាន (សម្លេងអនុម័ត ៦៦/៦៦) ការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៤ (សម្លេងអនុម័ត ៦៦/៦៦) ការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឲ្យក្រុមហ៊ុនអាឡិចខបភើរេសិន (សម្លេងអនុម័ត ៦៦/៦៦) ការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងអាស៊ានស្តីពីបំលាស់ទីរូបវន្តបុគ្គល (សម្លេងអនុម័ត ៦៥/៦៥) ការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារទី៣នៃការធ្វើ វិសោធនកម្មកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋប្រជាមានិតចិន និងពិធីសារបញ្ចូលវិធានការអនាម័យ និងភូតគាមអនាម័យ និងរបាំងបច្ចេកទេស ពាណិជ្ជកម្មនៅក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ រវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋប្រជាមានិតចិន (សម្លេងអនុម័ត ៦៥/៦៥) ការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការ អនុម័តយល់ព្រមលើពិធីសារនិងពិធីសារទី២ដើម្បីធ្វើវិសោធនកម្មកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទំនិញនៅក្រោមកិច្ចព្រមព្រៀង

ក្របខ័ណ្ឌស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយក្នុងចំណោមប្រទេសសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍និងសាធារណៈរដ្ឋកូរ៉េដែលមាន (សម្លេងអនុម័ត៦៥/៦៥) ការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារស្តីពីការធ្វើវិសោធនកម្មកិច្ចព្រមព្រៀងសេដ្ឋកិច្ចអាស៊ានមួយចំនួនដែលពាក់ព័ន្ធនឹងពាណិជ្ជកម្មទំនិញ (សម្លេងអនុម័ត៦៥/៦៥) និងការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ (សម្លេងអនុម័ត ៦៥/៦៥)។

ជាមួយគ្នានេះមានរបៀបវារៈចំនួន៣ ដែលរដ្ឋសភាបានបោះឆ្នោតមានដូចជា ការបោះឆ្នោតជាកញ្ចប់ដើម្បីជ្រើសតាំងប្រធាន អនុប្រធានរដ្ឋសភា ប្រធាន អនុប្រធានគណៈកម្មការជំនាញទាំងអស់នៃរដ្ឋសភា និងផ្តល់សេចក្តីទុកចិត្តចំពោះរាជរដ្ឋាភិបាល អាណត្តិទី៥ (អនុម័តយល់ព្រមដោយលើកដៃ ៦៨/៦៨) ការបោះឆ្នោតជ្រើសតាំងសមាជិកគណៈកម្មការជំនាញទាំងអស់នៃរដ្ឋសភា (យល់ព្រម ៦៥/៦៥) និងបោះឆ្នោតទុកចិត្តលើសមាសភាពសមាជិករាជរដ្ឋាភិបាល ដែលបាន កែសម្រួល និងបំពេញបន្ថែម (យល់ព្រម ៦៧/៦៧)។

ការពិភាក្សា និងអនុម័តលើសេចក្តីព្រាងច្បាប់ទាំង១០ មានអ្នកតំណាងរាស្ត្រ ៦៦រូប នៃគណបក្សប្រជាជនកម្ពុជាបានឡើងបញ្ចេញមតិ ដោយប្រើថេរៈវេលាសរុបចំនួន ១៣៦នាទី (ស្មើនឹង២ម៉ោង១៦នាទី)។

ចំពោះខ្លឹមសារការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រក្នុងសម័យប្រជុំសភា ការសង្កេតឃើញថា អ្នកតំណាងរាស្ត្រមកពីគណបក្សប្រជាជនកម្ពុជាបញ្ចេញមតិផ្តោតក្នុងន័យអព្យាក្រឹត៧០នាទី (ស្មើនឹង៥១%នៃការបញ្ចេញមតិសរុបរបស់គណបក្សខ្លួន) ក្នុងខ្លឹមសារអវិជ្ជមាន៦នាទី (ស្មើនឹង១%នៃការបញ្ចេញមតិរបស់គណបក្សសរុប) ចំណែកក្នុងខ្លឹមសារវិជ្ជមានវិញ អ្នកតំណាងរាស្ត្រគណបក្សនេះបានបញ្ចេញមតិ៦០នាទី (ស្មើនឹង៤៨%នៃចំនួនការបញ្ចេញមតិសរុបរបស់គណបក្សខ្លួន)។

### ២.៣ ការអនុម័តច្បាប់ដោយគ្មានការពិភាក្សា

សម្រាប់ដំណើរការរដ្ឋសភានីតិកាលទី៥នេះ ត្រូវបានគេវាយតម្លៃថា រដ្ឋសភាពឯកបក្សនឹងមិនអាចបំពេញតួនាទីរបស់ខ្លួនបានល្អនោះទេ។ តួនាទីមួយក្នុងចំណោមតួនាទីសំខាន់ៗជាច្រើនគឺការអនុម័តច្បាប់ត្រូវបានគេវាយតម្លៃថា រដ្ឋសភានីតិកាលនេះនឹងមិនមានការពិភាក្សាផុសផុលទៅលើសេចក្តីព្រាងច្បាប់ដែលបញ្ជូនពីរាជរដ្ឋាភិបាល។ ជាក់ស្តែងនៅដើមនីតិកាលនេះការសង្កេតឃើញថា ការប្រជុំអនុម័តលើសេចក្តីព្រាងច្បាប់របស់រដ្ឋសភាគឺមិនសូវមានការពិភាក្សាឲ្យបានផុសផុល និងស៊ីជម្រៅនោះទេ ដោយសេចក្តីព្រាងមួយចំនួនត្រូវបានអ្នកតំណាងរាស្ត្រ ពិភាក្សា តែមួយទៅពីរមាត្រាប៉ុណ្ណោះ ហើយក៏មានការអនុម័តតែម្តង។ ការសង្កេតបានរកឃើញថាមានសេចក្តីព្រាងច្បាប់ចំនួន៥ស្ទើរមិនមានការពិភាក្សាមុនធ្វើការអនុម័ត ដោយជាមធ្យមការអនុម័តច្បាប់នីមួយៗ ចំណាយពេលត្រឹមតែ៧នាទីក្នុងការពិភាក្សា។ សេចក្តីព្រាងច្បាប់ទាំងនោះរួមមាន ដូចខាងក្រោម៖

- សេចក្តីព្រាងច្បាប់ស្តីពីយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឲ្យក្រុមហ៊ុនអាឡិចខបភើរេសិន
- សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងអាស៊ានស្តីពីបំលាស់ទីរូបវន្តបុគ្គល
- សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារទី៣ នៃការធ្វើវិសោធនកម្មកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋប្រជាមានិតចិន

និងពិធីសារបញ្ចូលវិធានការអនាម័យនិងភូតគាមអនាម័យនិងរបាំងបច្ចេកទេសពាណិជ្ជកម្មនៅក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញនៃកិច្ចព្រម ព្រៀងក្របខ័ណ្ឌស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍នៃសាធារណរដ្ឋប្រជាមានិតចិន

- សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារទី២ ដើម្បីធ្វើវិសោធនកម្មកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទំនិញនៅក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយក្នុងចំណោមប្រទេសសមាជិកនៃសមាគម ប្រជាជាតិអាស៊ីអាគ្នេយ៍និងសាធារណរដ្ឋកូរ៉េ
- សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារស្តីពីការធ្វើវិសោធនកម្មកិច្ចព្រមព្រៀងសេដ្ឋកិច្ចអាស៊ានមួយចំនួនដែលពាក់ព័ន្ធនឹងពាណិជ្ជកម្មទំនិញ។

ដោយឡែកសេចក្តីព្រាងច្បាប់ថវិកាជាតិឆ្នាំ២០១៤វិញ សភាបានប្រើរយៈពេលតែមួយព្រឹកនៃការប្រជុំដើម្បីអនុម័តច្បាប់នោះ។ ទោះបីជាមានការប្រើរយៈពេលវែងជាក្នុងការអនុម័តសេចក្តីព្រាងច្បាប់នេះបើប្រៀបធៀបនឹងច្បាប់មួយចំនួនខាងលើក្នុងដំណើរការកិច្ចប្រជុំនោះមានការជជែកពិភាក្សាដេញដោរបន្តិចបន្តួចផងដែរ។ ភាគច្រើននៃរយៈពេលមួយព្រឹកនៃកិច្ចប្រជុំអនុម័តច្បាប់នោះ គឺបែរជាត្រូវបានចំណាយទៅលើការអានសេចក្តីព្រាងច្បាប់មួយជំពូកម្តង ដើម្បីធ្វើការអនុម័តតែប៉ុណ្ណោះ។

## III. សកម្មភាពរបស់អ្នកតំណាងរាស្ត្រ និងបេក្ខជនជាប់ឆ្នោត

### ៣.១ សកម្មភាពរបស់តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា

នៅក្នុងរយៈពេលមួយឆមាសនេះ តាមទិន្នន័យដែលខុមហ្វ្រែលទទួលបានពីបណ្តាញរបស់ខ្លួន គណបក្ស ការិយាល័យតំណាងរាស្ត្រ និងពីប្រព័ន្ធផ្សព្វផ្សាយនានាបានបង្ហាញឲ្យឃើញថា មានអ្នកតំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជាចំនួន៣៦រូប ស្មើនឹង៥៣% នៃចំនួនអ្នកតំណាងរាស្ត្រសរុបដែលមានចំនួន៦៨រូប បានចុះមូលដ្ឋានសរុប១៨៨លើក។

<u>**តារាងទី១៖ គោលបំណងនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា**</u>

| **គោលបំណងនៃការចុះមូលដ្ឋានទាំង ១៨៨លើករបស់តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា** | ៣៦រូប |
|---|---|
| ជួបសំណេះសំណាល សាកសួរសុខទុក្ខ ចែកអំណោយនិងការសម្ពោធសមិទ្ធផលនានា | ១៤៥ (៧៧%) |
| ការចុះពង្រឹងផ្ទៃក្នុង និងបណ្តាញគណបក្ស | ១៦ (៩%) |
| ការចុះអមដំណើរជាក្រុមឬអមដំណើរថ្នាក់ដឹកនាំ | ២៤ (១៣%) |
| ការចូលរួមក្នុងវេទិកាសាធារណៈ | ០៣ (១%) |
| ការអន្តរាគមន៍និងដោះស្រាយបញ្ហានានា | ០០ (០%) |
| **សរុបគោលបំណងតាមគណបក្ស** | **១៨៨ (១០០%)** |

តារាងទី១នេះ បង្ហាញពីការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រភាគច្រើនផ្តោតទៅលើគោលបំណងជួបសំណេះសំណាល សាកសួរសុខទុក្ខ ចែកអំណោយ និងសមិទ្ធិផលនានាដែលចុះបាន ១៤៥លើក (ស្មើនឹង៧៧%នៃការចុះមូលដ្ឋានសរុប)។ ចំពោះការចុះមូលដ្ឋាន ក្នុងគោលបំណងទី២ ដែលអ្នកតំណាងរាស្ត្រផ្តោត គឺការអមដំណើរថ្នាក់ដឹកនាំគណបក្សរបស់ខ្លួនចុះបាន២៤លើក (ស្មើនឹង១៣%នៃការចុះមូលដ្ឋានសរុប)។ ក្នុងគោលបំណងចុះពង្រឹងផ្ទៃក្នុងនិងបណ្តាញគណបក្សចុះបាន ១៦លើក (ស្មើនឹង៩%នៃចំនួនចុះមូលដ្ឋានសរុប)។ ចំណែកការចុះមូលដ្ឋានក្នុងគោលបំណងចូលរួមវេទិកា ឬសិក្ខាសាលាសាធារណៈចុះបាន០៣លើក(ស្មើនឹង១%នៃការចុះមូលដ្ឋានសរុប)។ ដោយឡែកក្នុងគោលបំណងអន្តរាគមន៍ និងដោះស្រាយបញ្ហានានារបស់ប្រជាពលរដ្ឋខុមហ្វ្រែលមិនបានទទួលព័ត៌មានទេ។

គួរបញ្ជាក់ដែរថា តារាងខាងលើ ខុមហ្វ្រែលសង្កេតឃើញថា តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា ការចុះមូលដ្ឋានគឺភាគច្រើនផ្តោតតែទៅលើការចុះសំណេះសំណាលសួរសុខទុក្ខប្រជាពលរដ្ឋ ដោយមិនមានសកម្មភាពអន្តរាគមន៍ និងដោះស្រាយបញ្ហានានារបស់ប្រជាពលរដ្ឋទេ។

**-ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា (៣៦រូប ចុះបានសរុប ១៨៨លើក) ខាងក្រោមនេះគឺជាករណីខ្លះៗនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រនៃគណបក្សនេះ៖**

អ្នកតំណាងរាស្ត្រ **ត្រឹងថាវី** មណ្ឌល**ក្រចេះ** អ្នកតំណាងរាស្ត្រ **ងួន ញ៉ិល** មណ្ឌល**កំពង់ធំ** និងអ្នកតំណាងរាស្ត្រ **ចាយ បូរិន** មណ្ឌល**កំពង់ចាម** ចុះមូលដ្ឋានច្រើនជាងគេ ក្នុងចំណោមអ្នកតំណាងរាស្ត្រគណបក្សខ្លួន។ កាលពីថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៤ អ្នកតំណាងរាស្ត្រ ត្រឹម ថាវី បានអញ្ជើញចុះមូលដ្ឋាននៅក្នុងសង្កាត់ក្រចេះ ក្រុងក្រចេះ ខេត្តក្រចេះ ក្នុងគោលបំណងដើម្បីជួបសំណេះសំណាលជាមួយមន្ត្រីនៃមន្ទីរអប់រំខេត្តក្រចេះនិងលោកគ្រូ អ្នកគ្រូសរុបចំនួនប្រហែល ១៥០ នាក់។ អ្នកតំណាងរាស្ត្រ ងួន ញ៉ិល មណ្ឌលកំពង់ធំកាល កាលពីព្រឹកថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៣ នៅក្នុងបរិវេណវត្តឈើទាលស្ថិតនៅក្នុងឃុំកំពង់ចិនត្បូង ស្រុកស្ទោង ខេត្តកំពង់ធំ និងមានពីធីចែកអំណោយជូនដល់បងប្អូនប្រជាពលរដ្ឋ ដែលទទួលរងនូវគ្រោះ ទឹកជំនន់ចំនួន៨ឃុំ ស្ថិតនៅក្នុងស្រុកស្ទោង ព្រមទាំងថ្នាក់ដឹកនាំខេត្ត និងអាជ្ញាធរមូលដ្ឋានជាច្រើនរូប និងលោកយាយ លោកតាប្រជាពលរដ្ឋមកទទួលអំណោយចំនួន៥១០គ្រួសារ។ ចំពោះ អ្នកតំណាងរាស្ត្រ **ចាយ បូរិន** មណ្ឌលកំពង់ចាម កាលពីថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៣ អ្នកតំណាងរាស្ត្របានអញ្ជើញចូលរួមក្នុងពិធីសាកសួរសុខទុក និងចែកអំណោយដល់ប្រជាពលរដ្ឋរងគ្រោះដោយសារទឹកជំនន់ ដែលបានប្រព្រឹត្តនៅបរិវេណវត្តព្រះធាតុ ស្រុកកំពង់សៀម ខេត្តកំពង់ចាម ដោយបាននាំយកអំណោយជាអង្ករចំនួន៨៧តោន៥០០គីឡូក្រាម របស់រដ្ឋសភា យកមកចែកជូនពលរដ្ឋរងគ្រោះដោយទឹកជំនន់ចំនួន ៣គ្រួសារ៤៧៦. មកពីឃុំ ២ របស់ស្រុកកំពង់សៀម ។

**៣.២ សកម្មភាពរបស់បេក្ខជនជាប់ឆ្នោតគណបក្សសង្គ្រោះជាតិ**

នៅក្នុងរយៈពេលមួយឆមាសនេះ តាមទិន្នន័យដែលខុមហ្វ្រែលទទួលបានពីបណ្តាញរបស់ខ្លួន គណបក្ស និងពីប្រព័ន្ធផ្សព្វផ្សាយនានាបានបង្ហាញឲ្យឃើញថា មានអ្នកបេក្ខជនជាប់ឆ្នោតពីគណបក្សសង្គ្រោះជាតិចំនួន៣៨រូប ស្មើនឹង៦៩% នៃចំនួនអ្នកបេក្ខជនជាប់ឆ្នោតសរុបដែលមានចំនួន៥៥រូប បានចុះមូលដ្ឋាន/ធ្វើសកម្មភាពសរុប ២១២លើក។

**<u>តារាងទី២៖ គោលបំណងនៃការចុះមូលដ្ឋានរបស់អ្នកបេក្ខជនជាប់ឆ្នោតគណបក្សសង្គ្រោះជាតិ</u>**

| **គោលបំណងនៃការចុះមូលដ្ឋានទាំង ២១២លើករបស់បេក្ខជនជាប់ឆ្នោតគណបក្សសង្គ្រោះជាតិ** | ៣៨រូប |
|---|---|
| ជួបសំណេះសំណាល សាកសួរសុខទុក្ខ និងចែកអំណោយ | ១១០ (៥២%) |

| | |
|---|---|
| ការចុះពង្រឹងផ្ទៃក្នុង និងបណ្តាញគណបក្ស | ៨២ (៣៩%) |
| ការចុះអមដំណើរជាក្រុមឬអមដំណើរថ្នាក់ដឹកនាំ | ១១ (៥%) |
| ការចូលរួមក្នុងវេទិកាសាធារណៈ | ០២ (១%) |
| ការអន្តរាគមន៍ និងដោះស្រាយបញ្ហានានា | ០៧ (៣%) |
| **សរុបគោលបំណងតាមគណបក្ស** | **២១២ (១០០%)** |

តារាងទី១នេះ បង្ហាញពីការចុះមូលដ្ឋានរបស់អ្នកបេក្ខជនជាប់ឆ្នោតភាគច្រើនផ្តោតទៅលើគោលបំណងចុះមូលដ្ឋានជួបសំណេះសំណាល សាកសួរសុខទុក្ខ និងចែកអំណោយចុះបាន១១០លើក(ស្មើនឹង៥២%នៃការចុះមូលដ្ឋានរបស់បក្សខ្លួនសរុប)។ ចំពោះគោលបំណងទី២ ដែលបេក្ខជនជាប់ឆ្នោតផ្តោតនោះគឺការចុះពង្រឹងផ្ទៃក្នុង និងបណ្តាញគណបក្សដែលចុះបាន៨២លើក (ស្មើនឹង៣៩%នៃការចុះមូលដ្ឋានរបស់បក្សខ្លួនសរុប)។

ក្នុងគោលបំណងចុះអមដំណើរថ្នាក់ដឹកនាំចុះបាន ១១លើក (ស្មើនឹង៥%នៃចំនួនចុះមូលដ្ឋានសរុប)។ ចំណែកការចុះមូលដ្ឋានក្នុងគោលបំណងចូលរួមវេទិកា ឬសិក្ខាសាលាសាធារណៈចុះបាន០២លើក(ស្មើនឹង១%នៃការចុះមូលដ្ឋានសរុប)។ ដោយឡែកក្នុងគោលបំណងអន្តរាគមន៍ និងដោះស្រាយបញ្ហានានារបស់ប្រជាពលរដ្ឋចុះបាន០៧លើក(ស្មើនឹង៣%នៃការចុះមូលដ្ឋានសរុប)។

គួរបញ្ជាក់ដែរថា តារាងខាងលើ ខុមហ្វ្រែលសង្កេតឃើញថា បេក្ខជនជាប់ឆ្នោតគណបក្សសង្គ្រោះជាតិ ការចុះមូលដ្ឋានគឺភាគច្រើនផ្តោតតែទៅលើការចុះពង្រឹងផ្ទៃក្នុង និងបណ្តាញគណបក្ស និងសកម្មភាព ជួបសំណេះសំណាល សាកសួរសុខទុក្ខ និងចែកអំណោយ។ ជាមួយគ្នាបានធ្វើសកម្មភាពអន្តរាគមន៍ និងដោះស្រាយបញ្ហានានារបស់ប្រជាពលរដ្ឋផងដែរ។

**-ការចុះមូលដ្ឋានរបស់បេក្ខជនជាប់ឆ្នោតគណបក្សសង្គ្រោះជាតិ (៣៨រូប ចុះបានសរុប ២១២លើក) ខាងក្រោមនេះគឺជាករណីខ្លះៗនៃការចុះមូលដ្ឋានរបស់អ្នកបេក្ខជនជាប់ឆ្នោតនៃគណបក្សនេះ៖**

បេក្ខជនជាប់ឆ្នោត **កឹម សុខា** មណ្ឌល**កំពង់ចាម** បេក្ខជនជាប់ឆ្នោត **គង់ បូរ៉ា** មណ្ឌលព្រៃវែងនិងបេក្ខជនជាប់ឆ្នោត**យ៉ែម បុញ្ញឫទ្ធិ** មណ្ឌល**ព្រៃវែង** បានចុះមូលដ្ឋានច្រើនជាងគេ ក្នុងចំណោមបេក្ខជនជាប់ឆ្នោតគណបក្សខ្លួន។ កាលពីថ្ងៃទី០៧ខែកុម្ភៈឆ្នាំ២០១៤ ឯកឧត្តម **គង់ បូរ៉ា** បានអញ្ជើញចុះទៅសួរសុខទុក្ខនិងសំណេះសំណាលជួបជាមួយក្រុមដឹកនាំគណបក្ស ប្រចាំមូលដ្ឋាន និងប្រជាពលរដ្ឋអ្នកគាំទ្រគណបក្ស នៅទីស្នាក់ការគណបក្សប្រចាំស្រុកបាភ្នំ ខេត្តព្រៃវែង ពីធីនេះដោយមានអ្នកចូលរួមប្រមាណជិត ១០០០ នាក់។ កាលពីថ្ងៃទី១៣ ខែកុម្ភៈឆ្នាំ២០១៤ បេក្ខជនជាប់ឆ្នោត ឯកឧត្តម **កឹម សុខា** បានអញ្ជើញចុះជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋ និងសកម្មជនមូលដ្ឋានរបស់ខ្លួន ដែលបានរៀបចំឡើងនៅទីស្នាក់ការគណបក្សសង្គ្រោះជាតិ ខេត្តកំពង់ស្ពឺ ស្ថិតនៅភូមិស្មោរទី១ សង្កាត់ច្បារមន ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ដោយមានអ្នកចូលរួមប្រមាណជាង១០០០ នាក់។ ចំណែក បេក្ខជនជាប់ឆ្នោត **យ៉ែម បុញ្ញឫទ្ធិ** មណ្ឌលព្រៃវែង បានចុះទៅជួបសំណេះសំណាលជាមួយថ្នាក់ដឹកនាំថ្នាក់មូលដ្ឋានរបស់គណបក្សប្រចាំនៅស្រុកពាមរក៍ និងប្រជាពលរដ្ឋដែលមានចំនួនប្រមាណជិត១០០០ នាក់ នៅរសៀលថ្ងៃទី០៩ ខែកុម្ភៈឆ្នាំ២០១៤ នៅស្រុកពាមរក៍ ខេត្តព្រៃវែង ។

### ៣.៣ សកម្មភាពរបស់តំណាងគណបក្សប្រជាជនកម្ពុជាធៀបនឹងសកម្មភាពបេក្ខជនជាប់ឆ្នោតរបស់គណបក្សសង្គ្រោះជាតិ

ខាងក្រោមគឺជាការប្រៀបធៀបអំពីចំនួនជារូប និងចំនួនទៅតាមគោលបំណងនៃការចុះមូលដ្ឋាន/ការធ្វើសកម្មភាពរបស់តំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជា និងបេក្ខជនជាប់ឆ្នោតពីគណបក្សសង្គ្រោះជាតិ។

**<u>ក្រាហ្វិកទី១៖ ចំនួននៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា ធៀបនឹងបេក្ខជនជាប់ឆ្នោតគណបក្សសង្គ្រោះជាតិ</u>**




បើប្រៀបធៀបនៃការចុះមូលដ្ឋាន/ការធ្វើសកម្មភាពរបស់អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា និងបេក្ខជនជាប់ឆ្នោតរបស់គណបក្សសង្គ្រោះជាតិ នៅក្នុងចន្លោះពេលនេះឃើញថា ចំនួនចុះមូលដ្ឋាន/ធ្វើសកម្មភាពរបស់តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា និងបេក្ខជនជាប់ឆ្នោតគណបក្សសង្គ្រោះជាតិប្រហាក់ប្រហែលគ្នា។

តាមទិន្នន័យដែលខុមហ្វ្រែលទទួលបាន អ្នកតំណាងរាស្ត្រមកពីគណបក្សប្រជាជនកម្ពុជាបានចុះមូលដ្ឋានសរុប ១៨៨លើក។ ដោយឡែកបេក្ខជនជាប់ឆ្នោតរបស់គណបក្សសង្គ្រោះជាតិបានធ្វើសកម្មភាពនៅមូលដ្ឋានសរុប ២១២លើក ។

**<u>តារាងទី៣៖ ការប្រៀធៀបចំនួននៃការចុះមូលដ្ឋាន/ការធ្វើសកម្មភាពតាមគោលបំណងរវាងតំណាងស្រ្តគណបក្សប្រជាជនកម្ពុជា និងអ្នកបេក្ខជនជាប់ឆ្នោតគណបក្សសង្គ្រោះជាតិ</u>**

| **គោលបំណងនៃការចុះមូលដ្ឋានទាំង ៣១១លើករបស់តំណាងរាស្ត្រ និងបេក្ខជនជាប់ឆ្នោត** | ៣៦រូប | ៣៨រូប | **សរុបគោលបំណង** |
|---|---|---|---|
| ជួបសំណេះសំណាល សាកសួរសុខទុក្ខ ចែកអំណោយ និងការសម្ពោធសមិទ្ធផលនានា | ១៤៥ (៧៣%) | ១១០ (៤០%) | ២៥៥ (៥៦%) |
| ការចុះពង្រឹងផ្ទៃក្នុង និងបណ្តាញគណបក្ស | ១៦ (១០%) | ៨២ (៤៧%) | ៩៨ (២៩%) |
| ការចុះអមដំណើរជាក្រុមឬអមដំណើរថ្នាក់ដឹកនាំ | ២៤ (១៥%) | ១១ (៧%) | ៣៥ (១១%) |
| ការចូលរួមក្នុងវេទិកាសាធារណៈ | ០៣ (២%) | ០២ (១%) | ៥ (២%) |
| ការអន្តរាគមន៍ និងដោះស្រាយបញ្ហានានា | ០០ (០%) | ០៧ (៥%) | ៧ (២%) |
| **សរុបគោលបំណងតាមគណបក្ស** | **១៨៨ (១០០%)** | **២១២ (១០០%)** | **៤០០ (១០០%)** |

**ក្រាហ្វិកទី២៖ ភាគរយចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ/បេក្ខជនជាប់ឆ្នោតតាមគណបក្សធៀបភាគរយនៃអាសនៈសភា**




ការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រតាមគណបក្សធៀបទៅនឹងភាគរយនៃអាសនៈសភា តាមគណបក្សក្នុងអំឡុងរយៈពេលឆមាសនេះ ឃើញថា តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា ដែលមានអាសនៈ ៥៥% នៅក្នុងរដ្ឋសភា បានចុះមូលដ្ឋាន ៤៧% នៃចំនួនចុះមូលដ្ឋានសរុប។

បេក្ខជនជាប់ឆ្នោតគណបក្សសង្គ្រោះជាតិ ដែលមានអាសនៈ ៤៥%នៅក្នុងរដ្ឋសភា បានចុះមូលដ្ឋានបាន ៥៣% នៃការធ្វើសកម្មភាពសរុប។

### ៣.៣ ដំណើរការមិនប្រក្រតីនៃការិយាល័យតំណាងរាស្ត្រ

ការិយាល័យតំណាងរាស្ត្រជាទីកន្លែងធ្វើការងាររបស់អ្នកតំណាងរាស្ត្រនៅពេលដែលតំណាងរាស្ត្រចុះមូលដ្ឋាននោះ និងជាកន្លែងផ្សារភ្ជាប់ទំនាក់ទំនងរវាងតំណាងរាស្ត្រ និងម្ចាស់ឆ្នោត។ លើសពីនេះ ការិយាល័យតំណាងរាស្ត្រក៏ជាទីកន្លែងមួយដែលសម្រាប់បម្រើដល់ផលប្រយោជន៍ប្រជាពលរដ្ឋដោយមិនប្រកាន់ពីគណបក្សនយោបាយ និងជាកន្លែងមួយសម្រាប់ទទួលយកពាក្យបណ្ដឹងរបស់ប្រជាពលរដ្ឋ ដើម្បីផ្ញើជូនទៅអ្នកតំណាងរាស្ត្រដែលជាអ្នកតំណាងរបស់ខ្លួនធ្វើការដោះស្រាយពិភាក្សាគ្នានៅក្នុងរដ្ឋសភា។

ក្នុងដើមនីតិកាលទី៥នេះ អ្នកសង្កេតការណ៍ខុមហ្វ្រែលប្រចាំក្នុងរាជធានី ខេត្តទាំងអស់ បានសង្កេតឃើញថា ដំណើរការនៃការិយាល័យតំណាងរាស្ត្រនៅតាមបណ្ដាខេត្តមួយចំនួនហាក់មានដំណើរការមិនប្រក្រតី ព្រោះមិនបានបំពេញតួនាទីការងាររបស់ខ្លួនឡើយ ដោយបានបិទទ្វារមិនដំណើរការ ឬដំណើរការមិនពេញលេញ។

ខេត្តចំនួន៣ដែលខុមហ្វ្រែលរកឃើញថា នៅមិនទាន់មានការិយាល័យតំណាងរាស្ត្រដូចជា ខេត្តកែប ខេត្តមណ្ឌលគីរី និងខេត្តឧត្ដរមានជ័យ ។

ខុមហ្វ្រែលបានពិនិត្យឃើញដែលថា ក្នុងចំណោមរាជធានី ខេត្ត ដែលមានការិយាល័យតំណាងរាស្ត្រ មានការិយាល័យចំនួន១៧បានបើកដំណើរការ និងបំពេញតួនាទីការងាររបស់ខ្លួនរួមមានខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តកំពង់ចាម ខេត្តកំពង់ធំ ខេត្តកំពត ខេត្តកណ្ដាល ខេត្តប៉ៃលិន ខេត្តកោះកុង ខេត្តក្រចេះ ខេត្តព្រះវិហារ ខេត្តសៀមរាប ខេត្តព្រះសីហនុ ខេត្តស្ទឹងត្រែង ខេត្តស្វាយរៀង ខេត្តតាកែវ ខេត្តកំពង់ឆ្នាំង និងរាជធានីភ្នំពេញ។ ទន្ទឹមនឹងនេះក៏មានសេចក្ដីរាយការណ៍ថាការិយាល័យមួយចំនួនដែលបើកដំណើរការនោះនៅមិនទាន់អនុវត្តតួនាទីរបស់ខ្លួនពេញលេញនៅឡើយ។

ដោយឡែកការិយាល័យតំណាងរាស្ត្រក្នុងខេត្តចំនួនបីមិនសូវបានបើកដំណើរការ និងបំពេញតួនាទីការងាររបស់ខ្លួនទេ ក្នុងនោះរួមមានការិយាល័យក្នុងខេត្តកំពង់ស្ពឺ ខេត្តព្រៃវែង និងខេត្តពោធិ៍សាត់។

## IV. សង្ខេបព្រឹត្តិការណ៍សំខាន់ៗទាក់ទងសភា និងតំណាងរាស្ត្រ

### ៤.១ ភាពចម្រូងចម្រាសក្នុងការកោះប្រជុំសភាដំបូងរបស់ព្រះមហាក្សត្រ

ព្រះមហាក្សត្រមានព្រះរាជតួនាទីសំខាន់ណាស់នៅក្នុងការដោះស្រាយភាពទាល់ច្រកនយោបាយ។ ព្រះអង្គមានតួនាទីជាឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ជាឧត្តមក្រុមប្រឹក្សាការពារជាតិ ពិសេសទៅទៀតនោះ នៅពេលប្រទេសមានបញ្ហាផ្នែកនយោបាយព្រះអង្គមានតួនាទីខ្ពង់ខ្ពស់ជាអាជ្ញាកណ្តាល ដើម្បីធានាការប្រព្រឹត្តទៅនៃអំណាចសាធារណៈឲ្យមានភាពទៀងទាត់។

នៅក្រោយការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥នេះ គណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិដែលទទួលបានអាសនៈក្នុងការបោះឆ្នោតនេះមិនចុះសម្រុងគ្នាចំពោះលទ្ធផលនៃការបោះឆ្នោត និងការចូលរួមបង្កើតរដ្ឋសភាជាដើម។ បញ្ហានេះត្រូវបានគេសង្ឃឹមថា អង្គព្រះមហាក្សត្រ អាចនឹងដើរតួនាទីដើម្បីដោះស្រាយការជាប់គាំងនយោបាយ។ មិនទាន់មានការដោះស្រាយបញ្ហាដំណោះនិងជាប់គាំងនយោបាយប៉ុន្តែព្រះមហាក្សត្រ សម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ទ្រង់បានកោះអញ្ជើញបេក្ខជនជាប់ឆ្នោតទាំង ១២៣រូប ដើម្បីចូលរួមប្រជុំរដ្ឋសភាជាលើកដំបូង នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ ២០១៣។

ខ្លឹមសារព្រះរាជសាររបស់ព្រះមហាក្សត្រព្រះបាទ នរោត្តម សីហមុនី បានបញ្ជាក់ថា ព្រះអង្គសូមឯកឧត្តម និងលោកជំទាវ សមាជិកគណបក្សសង្គ្រោះជាតិ មេត្តាអញ្ជើញចូលរួមក្នុងសម័យប្រជុំសភាដំបូង ដើម្បីបង្ហាញនូវការរួបរួមជាតិ និងឯកភាពជាតិ។

ឆ្លើយតបទៅនឹងការកោះអញ្ជើញនេះ បេក្ខជនជាប់ឆ្នោតរបស់គណបក្សសង្គ្រោះជាតិ ប្រកាសជំហរមិនចូលរួមសម័យប្រជុំសភាដំបូងឡើយ។

ជុំវិញការបើកកិច្ចប្រជុំសភាកាលពីថ្ងៃទី២៣ កញ្ញា ដោយឯកបក្ស ពោលគឺមានតែគណបក្សប្រជាជនកម្ពុជា ត្រូវបានគេមើលឃើញថា កម្ពុជាបានដើរថយពីលទ្ធិប្រជាធិបតេយ្យ និងរំលោភរដ្ឋធម្មនុញ្ញ និងបានធ្វើឲ្យកម្ពុជាបានជួបវិបត្តិនយោបាយអស់រយៈពេលជាង៦ខែមកហើយចាប់តាំងពីបង្កើតរដ្ឋសភា។

### ៤.២ ការចរចារកដំណោះស្រាយនៅក្រោយការបោះឆ្នោតរបស់គណបក្សជាប់ឆ្នោត

បន្ទាប់ពីបរាជ័យក្នុងការចចារ ជាច្រើនលើកច្រើនសារួចមក គណបក្សសង្គ្រោះជាតិ និងគណបក្សប្រជាជនកម្ពុជាបានវិលត្រឡប់មករកតុចចារសាជាថ្មី កាលពីថ្ងៃទី១៨ ខែកុម្ភៈ និងថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៤នេះ ដែលជាជំជួបចរចាលើកទី០៨ហើយនៅថ្ងៃទី០៩និងថ្ងៃទី២០ខែសីហាឆ្នាំ២០១៤ នៅថ្ងៃទី១៤ខែកញ្ញាឆ្នាំ២០១៤ នៅថ្ងៃទី៥ខែវិច្ឆិការឆ្នាំ២០១៤ នៅថ្ងៃទី១០ខែមិនាឆ្នាំ២០១៤ ក្នុងនោះមានជំជួបថ្នាក់ដឹកនាំកំពូលចំនួនពីរលើកផងដែរនៅថ្ងៃ១៦ និង១៧ ខែកញ្ញា ឆ្នាំ២០១៣។ បើទោះជាមានការព្រមព្រៀងលើការកែទម្រង់ការបោះឆ្នោតនៅការចរចាចុងក្រោយនេះ ការមិនចុះសម្រុងគ្នាកន្លងមកត្រូវបានមើលឃើញថា កើតមកពីការមិនទុកចិត្តគ្នា និងការបកស្រាយរដ្ឋធម្មនុញ្ញផ្ទុយគ្នា។

ជម្លោះនយោបាយកើតឡើងនៅបន្ទាប់ពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានប្រកាសថាគណបក្សប្រជាជនកម្ពុជាឈ្នះឆ្នោតដោយទទួលបានអាសនៈចំនួន៦៨ រីឯគណបក្សសង្គ្រោះជាតិទទួលបាន៥៥កៅអី។ ជម្លោះនេះបានធ្វើឲ្យកម្ពុជាបានជួបវិបត្តិនយោបាយអស់រយៈពេលជាង៦ខែមកហើយ។

ជុំវិញលទ្ធផលនេះគណបក្សសង្គ្រោះជាតិតែងតែអះអាងថា គណបក្សរបស់ខ្លួនជាអ្នកឈ្នះការបោះឆ្នោតនេះ ពោលគឺឈ្នះ៦៣អាសនៈក្នុងចំណោមអាសនៈសរុប ១២៣។ ជម្លោះនយោបាយនៅក្រោយការបោះឆ្នោតនេះវាតែងតែកើតមានឡើង ហើយសម្រាប់សម្រាប់អាណត្តិទី៥នេះវាងបាន និងបន្តអូសបន្លាយ ហើយដំណោះស្រាយនៃបញ្ហានេះហាក់នៅវែងឆ្ងាយនៅឡើយ។

អាជ្ញាធរបានចាត់វិធានការបំបែកការតវ៉ា និងបានដាក់បំរាមហាមឃាត់ការជួយជុំតវ៉ានានាចាប់ការបំបែកការតវ៉ាដឹកនាំដោយគណបក្សសង្គ្រោះជាតិនៅទីលានប្រជាធិបតេយ្យកាលពីថ្ងៃទី០៤ ខែមករា ហើយបានចេញបំរាមមិនឲ្យមានការប្រមូលផ្តុំលើសពី១០នាក់។

ដើម្បីទម្លាយភាពទាល់ច្រកនេះ គណបក្សទាំងពីរគួរលើករបៀបវារៈទាក់ទងកំណែទម្រង់ការបោះឆ្នោត (កំណែទម្រង់ច្បាប់បោះឆ្នោត បញ្ជីបោះឆ្នោត និងអាជ្ញាធររៀបចំការបោះឆ្នោតជាដើម) និងកំណែទម្រង់បញ្ហាជាតិមួយចំនួនទៀតដោយគណបក្សប្រឆាំងត្រូវចូលរដ្ឋសភា ដើម្បីចូលរួមពិនិត្យ និងអនុម័តច្បាប់ពាក់ព័ន្ធនានា។ លើសពីនេះការបែងចែកអំណាច (តុល្យភាពអំណាច) នៅក្នុងរដ្ឋសភាជាតិក៏ជាប្រធានបទដែលគណបក្សទាំងពីរគួរបន្តលើមកពិភាក្សា ដើម្បីធានាថា កំណែទម្រង់ទាំងនេះអាចទទួលយកបានរវាងគណបក្សទាំងពីរ និងបំរើឲ្យប្រយោជន៍ជាតិ។

### ៤.៣ ជំហរមិនចូលរួមក្នុងសភារបស់គណបក្សសង្គ្រោះជាតិ

នៅបន្ទាប់ពីការប្រជុំសភាដំបូង គណបក្សសង្គ្រោះជាតិបានបញ្ជាក់ជំហរថា បើមិនមានការអង្កេតឯករាជមួយដើម្បីរកការពិតទាងទងលទ្ធផលការបោះឆ្នោត និងការកែទម្រង់បញ្ហាជាតិសំខាន់ៗទេ បេក្ខជនគណបក្សនេះនឹងមិនចូលរដ្ឋសភាឡើយ។

បន្ថែមលើនេះទៀតកន្លងមកគណបក្សសង្គ្រោះជាតិបានដឹកនាំធ្វើការតវ៉ាបាត់កម្មទ្រង់ទ្រាយធំមានរាប់សែននាក់ ឲ្យលោកនាយករដ្ឋមន្ត្រីហ៊ុន សែន ចុះចេញពីតំណែង ឬត្រូវមានការបោះឆ្នោតឡើងវិញ។ ជាមួយគ្នានេះក៏បានអំពាវនាវសុំសហគមន៍អន្តរជាតិ កុំទទួលស្គាល់រដ្ឋាភិបាលអាណត្តិទី៥នេះ និងបានព្រមានចំពោះក្រុមហ៊ុនអន្តរជាតិធំៗ សុំកុំចុះកុងត្រាជំនួញជាមួយរដ្ឋាភិបាលនេះ ពីព្រោះកុងត្រាទាំងនោះអាចត្រូវបដិសេធនៅពេលអនាគតជាដើម។

### ៤.៤ រដ្ឋសភាឯកបក្សទទួលរងការរិះគន់

គណបក្សប្រជាជនបានរៀបចំអង្គការនីតិបញ្ញត្តិដែលគ្រប់គ្រងតួនាទីដឹកនាំក្នុងរដ្ឋសភាទាំងអស់ ទាំងប្រធាន អនុប្រធានរដ្ឋសភា និងប្រធានគណៈកម្មាការជំនាញទាំង៩។ បញ្ហានេះត្រូវបានគេពិនិត្យឃើញថា ប្រព័ន្ធត្រួតពិនិត្យផ្ទៀងផ្ទាត់ចុះខ្សោយ ហើយអាចធ្វើឲ្យរដ្ឋាភិបាលធ្វើអ្វីបានស្រេចតែចិត្ត ព្រោះថារដ្ឋសភាមកពីគណបក្សតែមួយមិនអាចត្រួតពិនិត្យផ្ទៀងផ្ទាត់ ឬ អាចកោះហៅមន្ត្រីរដ្ឋាភិបាលគណបក្សខ្លួនមកឆ្លើយឲ្យមានប្រសិទ្ធិភាពទេ។

បើទោះជាមានការអះអាងពីមន្ត្រីជាន់ខ្ពស់គណបក្សប្រជាជនកម្ពុជា និងស្ថិតក្នុងជួរដឹកនាំរដ្ឋសភាថា នៅអាណត្តិថ្មីនេះនឹងមិនអត់ឱនដល់មន្ត្រីរដ្ឋាភិបាលណាដែលប្រព្រឹត្តកំហុសទេ ប៉ុន្តែសម្រាប់រដ្ឋសភានីតិកាលទី៥នេះទៀតក៏ទំនងជាពិបាកធ្វើដែរ ព្រោះថាមានតែគណបក្សមួយដឹកនាំទាំងស្ថាប័ននីតិប្រតិបត្តិ និងនីតិបញ្ញត្តិ។ ចំពោះរដ្ឋាភិបាលអាណត្តិទី៥នេះទាមទារ

ឲ្យមានការត្រួតពិនិត្យឲ្យខ្លាំងជាងអាណត្តិកន្លងមក ហើយស្របពេលដែលរាជរដ្ឋាភិបាលបានសន្យាថានឹងធ្វើការកែទម្រង់ស៊ីជំរៅចំពោះបញ្ហាជាតិមួយចំនួន។ ដូច្នេះតួនាទីរបស់សភាក្នុងការត្រួតពិនិត្យរឹតតែសំខាន់ និងចាំបាច់ ហើយគណបក្សទាំងពីរត្រូវធ្វើសម្បទានគ្នាទៅវិញទៅមក ដើម្បីឲ្យមានតុល្យភាពអំណាចក្នុងរដ្ឋសភា ដែលធ្វើឲ្យស្ថាប័ននេះពង្រឹងប្រព័ន្ធត្រួតពិនិត្យផ្ទៀងផ្ទាត់រដ្ឋាភិបាលឲ្យមានប្រសិទ្ធិភាព។

នៅក្រោយការបង្កើត រដ្ឋសភានីតិកាលទី៥នេះ ទទួលរងការរិះគន់ថា ជារដ្ឋសភារបស់បក្សប្រជាជន មិនមែនជារដ្ឋសភាជាតិ ដែលតំណាងឲ្យឆន្ទៈម្ចាស់ឆ្នោតទាំងមូលនោះទេ ព្រោះថាឆន្ទៈម្ចាស់ឆ្នោតពាក់កណ្ដាលទៀតមិនបានគាំទ្រនោះឡើយ។ មួយវិញទៀតមានការលើកឡើងថា ការបង្កើតរដ្ឋសភានេះបានរំលោភទៅនឹងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា លើចំណុចមួយចំនួនដូចជា រដ្ឋសភា មិនមានវត្តមានតំណាងរាស្រ្តយ៉ាងតិច១២០នាក់ និងរំលោភទៅនឹងគោលការលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សជាដើម។

### ៤.៥ គណបក្សកាន់អំណាចពិចារណាលទ្ធភាពដកហូតអាសនៈគណបក្សសង្រ្គោះជាតិ

ការមិនចូលរដ្ឋសភារបស់បេក្ខជនជាប់ឆ្នោតទាំង៥៥រូបរបស់គណបក្សសង្រ្គោះជាតិបានបង្កឲ្យមានប្រតិកម្មពីគណបក្សប្រជាជនកម្ពុជា។ ទាក់ទងការធ្វើពហិការមិនចូលរដ្ឋសភានេះត្រូវបានលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និងមន្ត្រីជាន់ខ្ពស់គណបក្សប្រជាជនកម្ពុជាបកស្រាយថាជាការបោះបង់អាសនៈ ហើយតាមច្បាប់បោះឆ្នោត គ.ជ.ប អាចយកទៅបែងចែកឲ្យគណបក្សផ្សេង។

នៅក្នុងកំឡុងខែធ្នូ ឆ្នាំ២០១៣ មន្ត្រីជាន់ខ្ពស់គណបក្សប្រជាជនកម្ពុជាបានបញ្ជាក់ឲ្យដឹងថាខ្លួនបានពិភាក្សាអំពីលទ្ធភាពស្នើឲ្យមានការទាត់ចោលអាសនៈចំនួន៥៥របស់គណបក្សសង្គ្រោះជាតិ និងគ្រោងស្នើឲ្យមានការធ្វើវិសោធនកម្មច្បាប់បោះឆ្នោតដើម្បីបញ្ចៀសវិបត្តិក្នុងរដ្ឋសភាក្រោយពីការបោះឆ្នោត ប៉ុន្តែមកដល់ពេលនេះនូវមិនមានការបង្ហាញជាផ្លូវការយ៉ាងណានោះទេចំពោះបញ្ហានេះ។

លើសពីនេះគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាបានធ្វើរបាយការណ៍ជុំវិញអវត្តមានរបស់បេក្ខជនតំណាងរាស្រ្តនៃកណបក្សសង្គ្រោះជាតិ ដើម្បីទូលថ្វាយព្រះមហាក្សត្រ បញ្ជូនទៅ គ.ជ.ប និងក្រុមប្រឹក្សាធម្មនុញ្ញផងដែរ។ ក៏នៅមិនទាន់មានការបញ្ជាក់ជាផ្លូវការយ៉ាងណាទេចំពោះករណីនេះ។

ជុំវិញករណីនេះដែរនាពេលថ្មីៗនេះអ្នកតំណាងរាស្រ្ត ជាម យៀប ប្រធានគណៈកម្មការហរិញ្ញវត្ថុ ធនាគារ និងសវនកម្មនៃរដ្ឋសភា បានបញ្ជាក់ឲ្យដឹងថា ប្រាក់ខែបេក្ខជនជាប់ឆ្នោតរបស់គណបក្សសង្គ្រោះជាតិកំឡុងពេល៦ខែកន្លងមកនេះ គឺត្រូវទុកជាសម្បត្តិរដ្ឋ។ បេក្ខជនជាប់ឆ្នោតទាំង ៥៥រូប នឹងទទួលបានប្រាក់ខែនៅបន្ទាប់ពីធ្វើសច្ចាប្រនិធានក្លាយជាតំណាងរាស្រ្តពេញសិទ្ធិ ហើយចំពោះប្រាក់ខែចាស់គឺស្ថិតនៅលើនាយករដ្ឋមន្ត្រីជាអ្នកកំណត់។

ចំពោះគម្រោងដកហូរអាសនៈនេះ មន្ត្រីជាងខ្ពស់គណបក្សសង្គ្រោះជាតិបានបកស្រាយថា ជាអំពើខុសច្បាប់ និងអាចនឹងរុញច្រានឲ្យកម្ពុជាធ្លាក់ក្នុងវិបត្តិនយោបាយកាន់តែធ្ងន់ធ្ងរ។ ទន្ទឹមនឹងនេះមន្ត្រីអង្គការសង្គមស៊ីវិលក៏បានធ្វើការបកស្រាយថាគម្រោងណាមួយក្នុងដកហូរអាសនៈរបស់គណបក្សសង្គ្រោះជាតិគឺជាអំពើខុសច្បាប់ ព្រោះថាច្បាប់បោះឆ្នោតបានចែងថា បើ

មានការប្រកាសបោះបង់ចោលអាសន្ន ទើប គ.ជ.ប អាចយកទៅបែងចែកឲ្យគណបក្សផ្សេង ប៉ុន្តែគណបក្សសង្គ្រោះជាតិមិនដែលប្រកាសបោះបង់ចោលអាសនៈនោះទេ។

### ៤.៦ តុលាការដោះហៅមេដឹកនាំគណបក្សសង្គ្រោះជាតិ

សាលាដំបូងរាជធានីភ្នំពេញបានកោះហៅមេដឹកនាំគណបក្សសង្គ្រោះជាតិលោក សម រង្ស៊ី និងលោក កឹម សុខា ដែលជាបេក្ខជនជាប់ឆ្នោត និងជាអនុប្រធានគណបក្សសង្គ្រោះជាតិឲ្យចូលបំភ្លឺជុំវិញបាតុកម្មអហិង្សារបស់កម្មករ។ ទាក់ទងអភ័យឯកសិទ្ធិនេះមានចំណោទសួរថា តើបេក្ខជនជាប់ឆ្នោត លោក កឹម សុខា មានអភ័យឯកសិទ្ធិជាអ្នកតំណាងរាស្ត្រដែរឬទេ?

បើករណីបកស្រាយរបស់គណបក្សប្រជាជនកម្ពុជាការកោះហៅលោក កឹម សុខា ឲ្យចូលខ្លួនមកបំភ្លឺនៅក្នុងតុលាការនោះ មានការបកស្រាយថាជាឧបសគ្គផ្លូវច្បាប់ ជាពិសេសទាក់ទងអភ័យឯកសិទ្ធិ ព្រោះថា កាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ ២០១៣ រដ្ឋសភាមានតំណាងរាស្ត្រទាំងអស់ចំនួន១២៣រូបដែលក្នុងនោះមានឈ្មោះលោក កឹម សុខា។ បើយោងតាមមាត្រា ៨០នៃរដ្ឋធម្មនុញ្ញកម្ពុជាចែងថា *«តំណាងរាស្ត្រខ្មែរមានអភ័យឯកសិទ្ធិ។ តំណាងរាស្ត្ររូបណាក៏ដោយមិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួន ដោយហេតុពីបានសម្តែងយោបល់ ឬបញ្ចេញមតិក្នុងបំពេញមុខងាររបស់ខ្លួនសោះឡើយ។ ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួន សមាជិកណាមួយនៃរដ្ឋសភានឹងអាចធ្វើទៅកើតលុះត្រាតែមានការយល់ព្រមពីរដ្ឋសភា ឬពីគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាក្នុងចន្លោះសម័យប្រជុំនៃរដ្ឋសភា វៀរលែងតែក្នុងករណីបទល្មើសព្រហ្មទណ្ឌជាក់ស្តែង។ ក្នុងករណីខាងលើនេះ ក្រសួងមានសមត្ថកិច្ចត្រូវធ្វើសេចក្តីរាយការជូនរដ្ឋសភា ឬជូនគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាជាបន្ទាន់ដើម្បីសម្រេច។ សេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ត្រូវដាក់ជូនសម័យប្រជុំរដ្ឋសភាខាងមុខ ដើម្បីអនុម័តតាមមតិភាគច្រើនពីរភាគបីនៃសមាជិករដ្ឋសភាទាំងមូល។ ក្នុងករណីទាំងអស់ខាងលើនេះ ការឃុំខ្លួន ការចោទប្រកាន់តំណាងរាស្ត្រណាមួយត្រូវផ្អាក ប្រសិនបើរដ្ឋសភាបានបញ្ចេញមតិឲ្យផ្អាកតាមមតិភាគច្រើនបីភាគបួននៃចំនួនសមាជិករដ្ឋសភាទាំងមូល។»*

ក្នុងករណីខាងលើលោក កឹម សុខា ទទួលបានអភ័យឯកសិទ្ធិ ហើយត្រូវបានតុលាការកោះហៅឲ្យចូលខ្លួនមកបំភ្លឺដោយពុំមានការស្នើសុំទៅរដ្ឋសភាដើម្បីសុំដកអភ័យឯកសិទ្ធិដូចនេះគឺការរំលោភច្បាប់។

ការអនុវត្តន៍របស់សាលាដំបូងរាជធានីភ្នំពេញនេះ បញ្ជាក់ថា បេក្ខជនជាប់ឆ្នោតរបស់គណបក្សសង្គ្រោះជាតិមិនត្រូវបានផ្តល់អភ័យឯកសិទ្ធិនោះទេ ហើយមានន័យថាបេក្ខជនជាប់ឆ្នោតរបស់គណបក្សសង្គ្រោះជាតិក៏មិនទាន់ក្លាយជាអ្នកតំណាងរាស្ត្រដែរ ដូច្នេះគេអាចនិយាយបានថា ដំណើរការរដ្ឋសភានីតិកាលទី៥នេះ នៅមិនទាន់ស្រប់ច្បាប់នៅឡើយ ព្រោះថា បើពិនិត្យទៅលើមាត្រា៧៦នៃរដ្ឋធម្មនុញ្ញដែលចែងថា*«រដ្ឋសភាមានសមាជិកតំណាងរាស្ត្រយ៉ាងតិច១២០រូប»*។

### ៤.៧ សកម្មភាពបេក្ខជនជាប់ឆ្នោតរបស់គណបក្សសង្គ្រោះជាតិក្រោយអំឡុងពេលបោះឆ្នោត

ក្រោយពីសភាជាតិនីតិកាលទី៥បានបង្កើតឡើងដោយការបើកប្រជុំដំបូងក្រោមវត្តមានព្រះមហាក្សត្រនិង បេក្ខជនជាប់ឆ្នោតគណបក្សប្រជាជនកម្ពុជាកាលពីថ្ងៃទី២៤ ខែកញ្ញា ២០១៣ គេសង្កេតឃើញថាបេក្ខជនជាប់ឆ្នោតមកពីគណបក្សសង្គ្រោះ

ជាតិដែលធ្វើពហិកាមិនចូលរួមប្រជុំសភា មួយចំនួន បានធ្វើសកម្មភាពយ៉ាងសកម្មក្នុងការចូលរួមរៀបចំ និងដឹកនាំបាតុកម្ម។ ចាប់ពេលបង្កើតសភាឯកបក្ស រហូតដល់ខែមករា ឆ្នាំ២០១៤ គេសង្កេតឃើញមានបាតុកម្មចំនួន២៥លើកនៅរាជធានីភ្នំពេញ ដែលចូលរួមឬដែលត្រូវបានរៀបចំ និងដឹកនាំដោយបេក្ខជនជាប់ឆ្នោតរបស់គណបក្សសង្គ្រោះជាតិ។ បាតុកម្មទាំងនោះធ្វើឡើងក្នុងគោលបំណងដ៏ធំ គឺដើម្បីរកយុត្តិធម៌ជូនប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោតដោយទាមទារឲ្យមានការស៊ើបអង្កេតភាពមិនប្រក្រតីនៃការបោះឆ្នោត ឬទាមទារឲ្យមានការបោះឆ្នោតឡើងវិញ។ បេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រមួយចំនួនក៏បានចូលរួមក្នុងបាតុកម្មទាមទារប្រាក់តំឡើងប្រាក់បៀវត្សរ៍ផងដែរ។ បេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិដែលចូលរួមយ៉ាងសកម្មរួមមានៈ បេក្ខជន គឹម សុខា មណ្ឌលកំពង់ចាម បេក្ខជន គួយ ប៊ុនរឿន មណ្ឌលកំពង់ចាម បេក្ខជន សុន ឆ័យ មណ្ឌលភ្នំពេញ បេក្ខជន ហូរ វ៉ាន់ មណ្ឌលភ្នំពេញ បេក្ខជន មួរ សុខហួរ មណ្ឌលបាត់ដំបង បេក្ខជនយឹម សុវណ្ណ មណ្ឌលភ្នំពេញ បេក្ខជន កែ សុវណ្ណរតន៍ បេក្ខជន ជូឡុង សូម៉ូរ៉ា មណ្ឌលភ្នំពេញ ។

## V. អនុសាសន៍សម្រាប់រដ្ឋសភា និងការកែទម្រង់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា

### ៥.១ ពង្រឹងការត្រួតពិនិត្យអំណាចគ្នារវាងគណបក្សកាន់រដ្ឋាភិបាល និងគណបក្សក្រៅរដ្ឋាភិបាលក្នុងសភា និងរវាងរាជរដ្ឋាភិបាល និងសភា

ក- មានអនុសាសន៍របស់បន្ទប់ស្ថានភាពអង្កេតការ សង្គមស៊ីវិលដែលស្នើជម្រើសក្នុងការបែងចែកការដឹកនាំគណៈកម្មការជំនាញសភាទាំង៩ ដែលក្នុងករណីមានជំរើសពីរសំរាប់ក្រុមគណបក្សកាន់រដ្ឋាភិបាល (បច្ចុប្បន្នគឺគណបក្សប្រជាជនកម្ពុជា) និងក្រុមគណបក្សក្រៅរដ្ឋាភិបាល (បច្ចុប្បន្នគឺគណបក្សសង្គ្រោះជាតិ)។

**<u>ជំរើសទី១៖</u>** គណបក្សសង្គ្រោះជាតិត្រូវធ្វើជាប្រធានរដ្ឋសភា, អនុប្រធានរដ្ឋសភាទាំងពីរត្រូវធ្វើដោយគណបក្សប្រជាជនកម្ពុជា ចំណែកគណបក្សសង្គ្រោះជាតិត្រូវគ្រប់គ្រង/ជាប្រធានទាំង៤គណៈកម្មការជំនាញ រីឯគណបក្សប្រជាជនកម្ពុជាគ្រប់គ្រង/ជាប្រធានទាំង៥គណៈកម្មាការជំនាញ។ ផ្ទុយមកវិញ

**<u>ជំរើសទី២៖</u>** គណបក្សប្រជាជនកម្ពុជាត្រូវធ្វើជាប្រធានរដ្ឋសភា, អនុប្រធានរដ្ឋសភាទាំងពីរត្រូវធ្វើដោយគណបក្សសង្គ្រោះជាតិ ចំណែកគណបក្សប្រជាជនកម្ពុជាត្រូវគ្រប់គ្រង/ជាប្រធានចំនួន៤គណៈកម្មាការជំនាញ រីឯគណបក្សសង្គ្រោះជាតិត្រូវគ្រប់គ្រង/ជាប្រធានទាំង៥គណៈកម្មាការជំនាញ។

ខ- ក្នុងនីតិកាលទី៥ នៃរដ្ឋសភា នាយករដ្ឋមន្ត្រី និងសមាជិករាជរដ្ឋាភិបាលនឹងត្រូវមកឆ្លើយឆ្លងយ៉ាងសកម្មជាមួយតំណាងរាស្ត្រ ស្របតាមបទបញ្ញត្តិ ដូចមានចែងនៅក្នុងមាត្រាទី៩៦ ជំពូកទី៧ មាត្រាទី១២១ថ្មី ជំពូកទី១០ នៃរដ្ឋធម្មនុញ្ញ និងមាត្រាទី១ ទី២ និងទី៨ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី។ ការមិនគោរព និងមិនអនុវត្តតាមមាត្រាខាងលើ សមាជិកសភានឹងធ្វើញ្ញត្តិស្តី បន្ទោស។ បើលើសបីដង សមាជិកសភានឹងធ្វើញ្ញត្តិដកការទុកចិត្តលើនាយករដ្ឋមន្ត្រី ឬសមាជិករាជរដ្ឋាភិបាល។ ហើយបើនៅបន្តមិនគោរព និងមិនអនុវត្តលើសពីប្រាំដង សមាជិកសភានឹងពិភាក្សាសំរេចអំពីការដកការទុកចិត្តទៅលើរាជរដ្ឋាភិបាល ឬគណៈរដ្ឋមន្ត្រី។

## ៥.២ យន្តការដឹកនាំ និងត្រួតពិនិត្យលើការអនុវត្តន៍កិច្ចសន្យានយោបាយអំពីកំណែទម្រង់

គ-បង្កើតគណៈកម្មការសភាចំរុះ ឬក្រុមប្រឹក្សាមួយ ស្តីពីកំណែទម្រង់ដែលមានសមាសភាពមកពីសមាជិកសភាគណបក្សប្រជាជនកម្ពុជា៩រូប និងគណបក្សសង្គ្រោះជាតិ៩រូប (ក្នុងនោះសមាជិកសភាម្នាក់របស់គណបក្សមកពីគណៈកម្មការបច្ចេកទេសរដ្ឋសភាមួយ) ដើម្បីដឹកនាំ និងត្រួតពិនិត្យមើលការអនុវត្តកំណែទម្រង់ (កិច្ចព្រមព្រៀងនយោបាយ)។ មានប្រធានផ្លាស់វេន្ត(មួយត្រីមាសម្តងរវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ)។

គណៈកម្មការសភាចំរុះ ឬក្រុមប្រឹក្សាស្តីពីកំណែទម្រង់មានសិទ្ធិសម្រេចលើយុត្តិសាស្រ្ត និងអំពីផែនការកំណែទម្រង់ព្រមទាំងរៀបចំកិច្ចប្រជុំសាធារណៈដែលកោះហៅរាជរដ្ឋាភិបាលរៀងរាល់មួយខែម្តងដើម្បីរាយការណ៍អំពីការអនុវត្តនៃកំណែទម្រង់។ អ្នកជំនាញការ និងតំណាងអង្គការសង្គមស៊ីវិលត្រូវបានអញ្ជើញដើម្បីចូលរួមសង្កេតការណ៍ និងផ្តល់របាយការណ៍ឯករាជ្យនៃការវាយតម្លៃលើការអនុវត្តន៍កំណែទម្រង់ផងដែរ។

## ៥.៣ វិសោធនកម្ម បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា

**ឃ-ការបង្កើតក្រុមឡើងបញ្ចេញមតិក្នុងសម័យប្រជុំពេញអង្គ៖** តំណាងរាស្រ្តមកពីគណបក្សតិចជាង១០អាសនៈមិនអាចបង្កើតក្រុមបញ្ចេញមតិឯករាជ្យដោយខ្លួនឯង ហើយតំណាងរាស្រ្តខ្លះត្រូវបាត់បង់សិទ្ធិបញ្ចេញមតិរបស់ខ្លួន និងខ្លះទៀតត្រូវទៅចូលរួមជាមួយគណបក្សដទៃដែលជាគូរប្រកួតប្រជែងដណ្តើមអំណាចរបស់ខ្លួន។ *ដូចនេះត្រូវធ្វើវិសោធនកម្មប្រការ៤៨ ថ្មី (ពីរ) នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា ដោយអនុញ្ញាតឲ្យគណបក្សដែលទទួលបានអាសនៈតិចជាង១០ អាចបង្កើតក្រុមបញ្ចេញមតិរបស់ខ្លួនបាន១។*

**ង.តម្លាភាព និងការចូលរួមពីម្ចាស់ឆ្នោតនៅក្នុងគណៈកម្មការជំនាញរដ្ឋសភា៖** ការសង្កេតបង្ហាញថា ការពិភាក្សាសេចក្តីព្រាងច្បាប់/ស្នើច្បាប់នៅសម័យប្រជុំពេញអង្គ គឺគ្រាន់តែជាវេទិកាបង្ហាញឲ្យល្អមើលតែប៉ុណ្ណោះ ដោយគ្រប់របៀបវារៈទាំងអស់ត្រូវបានអនុម័តជានិច្ច។ ទាំងថ្នាក់ដឹកនាំរាជរដ្ឋាភិបាល និងរដ្ឋសភាសុទ្ធតែបានលើកឡើងថា សេចក្តីព្រាងច្បាប់ៗត្រូវបានពិភាក្សាយ៉ាងស៊ីជម្រៅនៅក្នុងគណៈកម្មការជំនាញរដ្ឋសភា មុននឹងចូលដល់សម័យប្រជុំពេញអង្គដើម្បីរដ្ឋសភាអនុម័ត។ នៅខណៈដែលសម័យប្រជុំពេញអង្គបើកទូលាយឲ្យមានការចូលរួមសង្កេតពីម្ចាស់ឆ្នោត។ ការពិភាក្សានៅក្នុងគណៈកម្មការជំនាញបែរជាការសំងាត់ទៅវិញ និងមិនបើកឲ្យ មានការចូលរួមសង្កេតការណ៍ទៅវិញ។*អនុសាសន៍ ស្នើរដ្ឋសភាបើកទូលាយឲ្យមានការចូលរួមសង្កេតការរាល់ការពិភាក្សាសេចក្តីព្រាងច្បាប់/ស្នើច្បាប់នៅក្នុងគណៈកម្មការជំនាញរដ្ឋសភា ដើម្បីបង្កើនការចូលរួមរបស់ម្ចាស់ឆ្នោតទៅលើសេចក្តីព្រាងច្បាប់ និងតម្លាភាពក្នុងការពិភាក្សា។ រដ្ឋសភាគួរបើកចំហផងដែរឲ្យប្រជាពលរដ្ឋ សង្គមស៊ីវិល ផ្នែកឯកជន និងភាគីពាក់ព័ន្ធ មានលទ្ធភាព ចូលស្តាប់ និង/ឬផ្តល់យោបល់ និងសក្ខីកម្មក្នុងកិច្ចប្រជុំគណៈកម្មការជំនាញនីមួយៗរបស់រដ្ឋសភាជាមួយតំណាង រាជរដ្ឋាភិបាល*

*ច. ការទទួលស្គាល់ប្រធានមាន "ក្រុម"គណបក្សធំទាស់/ឬគណបក្សក្រៅរដ្ឋាភិបាល និងរដ្ឋាភិបាល "ស្រមោល"របស់ក្រុមគណបក្សធំទាស់។*

*ឆ. រដ្ឋសភាត្រូវបង្កើនសមត្ថភាព និងថវិកាសម្រាប់ការិយាល័យតំណាងរាស្រ្តដើម្បីឲ្យបុគ្គលិកអាចបំពេញតួនាទីរបស់ខ្លួនជាស្ពានរវាងប្រជាពលរដ្ឋនិងអ្នកតំណាងរាស្រ្ត និងជួសជុលកែលម្អអាគារការិយាល័យតំណាងរាស្រ្តចាស់ៗឡើងវិញ។*

*ជ. រដ្ឋសភាត្រូវបើកចំហឲ្យអ្នកសង្កេតការណ៍ ប្រជាពលរដ្ឋ សង្គមស៊ីវិល ផ្នែកឯកជន និងភាគីពាក់ព័ន្ធមានលទ្ធភាពចូលស្តាប់និង/ឬអង្កេតកិច្ចប្រជុំគណៈកម្មការជំនាញនីមួយៗរបស់រដ្ឋសភាជាមួយតំណាងរាជរដ្ឋាភិបាល*

### ៥.៤ វិសោធនកម្ម លក្ខន្តិកៈតំណាងរាស្ត្រ និងច្បាប់ឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

*ឈ. ដកមាត្រា៥ នៃលក្ខន្តិកៈតំណាងរាស្ត្រដើម្បីពង្រឹងអភ័យឯកសិទ្ធិសភាក្នុងការបញ្ចេញមតិនិងការធ្វើសកម្មភាពការពារដល់ប្រយោជន៍របស់ប្រជាពលរដ្ឋ។*

*ញ. សមាជិករដ្ឋសភាត្រូវមានការផ្តួចផ្តើម និងឆន្ទៈនយោបាយក្នុងការធ្វើវិសោធនកម្មមាត្រា១២០ នៃច្បាប់ ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដើម្បីធានានូវឯករាជភាព និងអំណាចរបស់សមាជិកសភា បុគ្គលម្នាក់ៗ ដោយមិនចងសមាជិកភាពអ្នកតំណាងរាស្ត្រទៅនឹងសមាជិកភាពរបស់គណបក្សនយោបាយ។*

### ៥.៥ ពង្រឹងសមត្ថភាពលេខាធិការដ្ឋានរដ្ឋសភា៖

*ដ. អគ្គលេខាធិការដ្ឋានរដ្ឋសភាត្រូវមានយន្តការច្បាស់លាស់មួយក្នុងការសម្រួលដល់ការបញ្ជូនឯកសារនានារបស់ប្រជាពលរដ្ឋទៅអ្នកតំណាងរាស្ត្រ។*

*ឋ. រដ្ឋសភាគួរផ្តល់សេចក្តីព្រាង/ស្នើច្បាប់នានាដល់ប្រជាពលរដ្ឋ ក៏ដូចជាអ្នកសង្កេតការណ៍ដែលចង់បានឯកសារទាំងនោះយកមកសិក្សាតាមការស្នើសុំ។*

*ឌ. រដ្ឋសភាត្រូវបង្កើនសមត្ថភាព និងថវិកាសម្រាប់ការិយាល័យតំណាងរាស្ត្រនៅតាមមណ្ឌលដើម្បីឱ្យបុគ្គលិកអាចបំពេញតួនាទីរបស់ខ្លួនជាស្ពានរវាងប្រជាពលរដ្ឋ និងអ្នកតំណាងរាស្ត្រ និងជួសជុលកែលម្អអាគារការិយាល័យតំណាងរាស្ត្រចាស់ៗឡើងវិញ។*

*ឍ. មន្ត្រីនៃអគ្គលេខាធិការដ្ឋានរដ្ឋសភាទាំងអស់ត្រូវមានជំហរអព្យាក្រឹត្យ។*